# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម





ករណីរបស់ជនជាប់ចោទលោក **នួន ជា** លោក **ខៀវ សំផន** និងលោក **អៀង សារី**

Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center

*...សុំអភ័យទោសដល់បងប្អូន ដែលបាត់បង់ឪពុកម្តាយ ញាតិសន្តាន ដែលមានវត្តមាននៅទីនេះ។ ខ្ញុំនិយាយតែការពិតទេ។ ខ្ញុំមិនមានស្អី ក្រៅពីហ្នឹងទេ ហើយខ្ញុំក៏មានបងប្អូនមានមាមីងខ្ញុំក៏បាត់បង់នៅពេល នោះដែរ ហើយបងៗដែលអ្នករងគ្រោះដែលជាអ្នកដឹកនាំក៏មានបងប្អូន គាត់បាត់ខ្លួននៅពេលនោះដែរ។*

**- សាក្សី លោក សួង ស៊ីគឿន**

## ផ្នែកទី១ ៖ ទិដ្ឋភាពទូទៅ

ក្រោយពេលពន្យារពេលសវនាការកាលពីថ្ងៃចន្ទ ដោយសារតែបញ្ហាសុខភាពទន់ខ្សោយរបស់ជនជាប់ចោទលោក **អៀង សារី** សវនាការបានបន្តនៅថ្ងៃអង្គារនេះ ដោយបានបញ្ចប់ការផ្តល់សក្ខីកម្មរបស់ **អុង ថុងហឿង** ដែលជាបញ្ញវន្តម្នាក់បានត្រឡប់មកប្រទេសកម្ពុជាវិញក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ហើយគាត់បានធ្វើការងារហត្ថកម្មនៅជំរំអប់រំរៀនសូត្រដើម្បីធ្វើការ "កសាង" ខ្លួន។ បន្ទាប់មកទៀត អង្គជំនុំជម្រះ បានកោះហៅលោក **សួង ស៊ីគឿន** ដែលជានាយកព័ត៌មាន និងឃោសនាការនៃក្រសួងការបរទេសដើម្បីមកបន្តសក្ខីកម្មរបស់គាត់។ លោក **សួង ស៊ីគឿន** បានបរិយាយពីក្រសួងការបរទេស រណសិរ្សរួបរួមជាតិកម្ពុជា និងរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ហើយនិងតួនាទីរបស់ **ប៉ុល ពត** ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យផងដែរ។ ដោយពិចារណាទៅលើសុខភាពទ្រុឌទ្រោមរបស់គាត់ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ការសួរដេញដោលគាត់ត្រឹមតែកន្លះថ្ងៃ។ ដើម្បីគ្រប់គ្រងពេលវេលាឲ្យមានប្រសិទ្ធភាព សាក្សីបម្រុងអ្នកស្រី **ស សៀក** (ដែលមានអត្តលេខ TCW-609) ដែលជាកម្មាភិបាលមួយរូបធ្វើការនៅក្រសួងឃោសនាការក្នុងអំឡុងនៃរបបនេះ បានចាប់ផ្តើមផ្តល់សក្ខីកម្មរបស់គាត់។ អ្នកស្រី **ស សៀក** បានផ្តោតទៅលើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ រចនាសម្ព័ន្ធក្រសួងឃោសនាការ និងការផ្សព្វផ្សាយវិទ្យុរបស់កម្ពុជាប្រជាធិបតេយ្យ។

បញ្ហានីតិវិធីជាច្រើន បានលេចឡើងនៅអំឡុងពេលសវនាការកាលពីថ្ងៃពុធ នៅពេលអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចមិនច្បាស់ ស្តីពីការណែនាំឯកសារទៅសាក្សី។ នៅខណៈដែលបញ្ហាទាំងនេះនៅតែពុំទាន់មានដំណោះស្រាយនៅឡើយ នៅចុងសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូង បានគូសបញ្ជាក់ថា អង្គជំនុំជម្រះ នឹងលើកយកបញ្ហានេះមកដោះស្រាយបន្ថែមក្នុងកិច្ចប្រជុំស្តីពីការគ្រប់គ្រងសវនាការ ដែលនឹងធ្វើឡើងនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ ខាងមុខនេះ។

## ផ្នែកទី២ ៖ សក្ខីកម្មសង្ខេបរបស់សាក្សី

នាសប្តាហ៍នេះ សាក្សីបីរូប បានផ្តល់សក្ខីកម្មយ៉ាងលម្អិត ស្តីពីបទពិសោធន៍ និងការចងចាំរបស់ពួកគាត់នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។

### ក. សក្ខីកម្មរបស់លោក អុង ថុងហឿង

សាក្សីលោក **អុង ថុងហឿង** គឺជាបញ្ញវន្តម្នាក់ដែលបានរស់នៅប្រទេសបារាំង ហើយបានឆ្លើយតបតាមការអំពាវនាវឲ្យចូលរួមចលនាស្នេហាជាតិនិយម និងបានវិលត្រឡប់មកប្រទេសកម្ពុជាវិញ ក្នុងឆ្នាំ១៩៧៦ ដើម្បីជួយកសាងប្រទេសជាតិឡើងវិញ។ នៅពេលមកដល់ គាត់ត្រូវបានគេនាំយកទៅទុកនៅជំរំលត់ដំ ជាទីកន្លែងដែលគាត់បានធ្វើការងារពលកម្ម។ ក្រោយពេលដែលរបបនោះបានដួលរំលំមក គាត់បានធ្វើការនៅ **សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង** អស់រយៈពីរខែ ដើម្បីជួយការងាររក្សាទុកឯកសារ ក៏ដូចជា ជួយបកប្រែឯកសាររបស់ **ស-២១** ផងដែរ។ ក្រោយមកទៀតគាត់បានបន្តដំណើរទៅជំរំជនភៀសខ្លួននៅក្នុងប្រទេសថៃ ជាទីកន្លែងដែលគាត់បានជួបនឹងប្រវត្តិវិទូ **ស្ទីវហេដឌ័រ** ។ នៅពេលដែលគាត់បានត្រឡប់ទៅអឺរ៉ុបវិញ គាត់បានធ្វើការជាមួយអ្នកស្រាវជ្រាវ និងប្រវត្តិវិទូជាច្រើន ដោយបកប្រែឯកសាររបស់កម្ពុជាប្រជាធិបតេយ្យ។

ក្នុងឆ្នាំ២០០៣ សាក្សី បានបោះពុម្ពសៀវភៅរបស់គាត់ដែលមានចំណងជើងថា *ខ្ញុំជឿលើខ្មែរក្រហម* ដោយផ្អែកទៅលើផ្នែកមួយចំនួននៃសារព័ត៌មាន ដែលតាមឲ្យដឹងមក គាត់បានរក្សាទុកក្នុងអំឡុងពេលនៃការកាន់អំណាចបក្សកុម្មុយនីស្តកម្ពុជា។ មេធាវីការពារក្តីឲ្យជនជាប់ចោទ **អៀង សារី** លោក **ម៉ៃខល កាណាវ៉ាស** បានព្យាយាមបង្ហាញពីវិមតិសង្ស័យទៅលើអត្ថិភាពនៃសារព័ត៌មាន ដោយគាត់បានចោទសួរពីហេតុផលអ្វីបានជាសារព័ត៌មានទាំងនោះ មិនត្រូវគេបានរឹបអូស នៅពេលដែលកម្មាភិបាលបានមកឆែកឆេររបស់របររបស់គាត់ នៅពេលដែលគាត់បានមកដល់ក្នុងឆ្នាំ១៩៧៦នេះ?[1] មេធាវី **កាណាវ៉ាស** ក៏បានមានបំណងគូសបង្ហាញពីភាពមិនស៊ីចង្វាក់គ្នាផងដែរ នៅក្នុងសក្ខីកម្មរបស់សាក្សី។ ផ្ទុយទៅវិញ មេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទលោក **ខៀវ សំផន** គឺលោកស្រី **អង់តា ហ្គីសសេ** បានប្រើប្រាស់សេចក្តីថ្លែងការណ៍របស់សាក្សី ដើម្បីធ្វើឲ្យអំណះអំណាងរបស់លោក **ខៀវ សំផន** កាន់តែរឹងមាំ ដោយថា **ខៀវ សំផន** គ្រាន់តែជាមនុស្សម្នាក់ដែលមានតែឋានៈខ្ពស់មួយរូបប៉ុណ្ណោះ ហើយមិនបានកាន់អំណាចពិតប្រាកដក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។

### *ក.១. ទំនាក់ទំនងសាក្សីជាមួយមេដឹកនាំរណសិរ្សរួបរួមជាតិកម្ពុជា*

ក្នុងអំឡុងពេលការសួរដេញដោលសាក្សី **អុង ថុងហឿង** ដោយ មេធាវី **កាណាវ៉ាស** សាក្សីបានពន្យល់ថា សេចក្តីថ្លែងការណ៍របស់គាត់ជាមួយសហចៅក្រមស៊ើបអង្កេត ស្តីពី "ឥទ្ធិពលយ៉ាងខ្លាំង" របស់លោក **អៀង សារី** មកលើព្រះអង្គម្ចាស់ **សីហនុ** ត្រូវបានផ្អែកលើការរកឃើញនៃ "អ្នកសង្កេតការណ៍ និងអ្នកធ្វើអត្ថាធិប្បាយរួមទាំងអស់។" គាត់បានសារភាពថា គាត់មិនមានទំនាក់ទំនងជិតស្និទ្ធជាមួយ **អៀង សារី** ឬព្រះអង្គម្ចាស់ **សីហនុ** ទេះ គាត់មិនដែលបាននិយាយទៅកាន់ **អៀង សារី** ដោយផ្ទាល់ទេ ហើយទំនាក់ទំនងគាត់ជាមួយសម្តេច **សីហនុ** គឺបានត្រឹមតែតាមរយៈការអំពាវនាវដ៏គួរសម ដែលព្រះអង្គបានអំពាវនាវទៅកាន់អាណិជនកម្ពុជា នៅពេលដែលព្រះអង្គបានយាងមកបំពេញទស្សនកិច្ចនៅក្នុងប្រទេសបារាំង ដើម្បីទទូចឲ្យនិស្សិតមកជួយធ្វើការតស៊ូប្រឆាំងនឹងរដ្ឋបាលលោក **លន់ នុល**។ សាក្សីបានបន្ថែមទៀតថា លោក **អៀង សារី** ក៏បានធ្វើការអំពាវនាវដូចគ្នានេះផងដែរ។

### *ក.២. ការត្រឡប់មកប្រទេសកម្ពុជាវិញក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ*

នៅពេលដែលមានការជជីកសួរពីហេតុផលដែលសាក្សី **អុង ថុងហឿង** បានរស់នៅប្រទេសបារាំងអស់រយៈពេល ១១ឆ្នាំ ទោះបីជាគាត់បានប្រកាសពីស្នេហាជាតិនិយម និងសេចក្តីប្រាថ្នារបស់គាត់ដើម្បីត្រឡប់មកប្រទេសកម្ពុជាវិញក៏ដោយ ក៏សាក្សីបានលើកឡើងពីហេតុផលផ្ទាល់ខ្លួនចំពោះភាពបរាជ័យក្នុងការវិលត្រឡប់មកវិញ។ គាត់បានសង្កត់ធ្ងន់ថា "ដល់ខ្ញុំមានជំនឿលើការណែនាំរបស់លោក **អៀង សារី** យើងខ្ញុំខ្មែរទាំងអស់ក៏វិលត្រឡប់មកស្រុកទាំងអស់គ្នា។" នៅពេលគាត់បានត្រឡប់មកវិញ គាត់បានដឹងថា ខ្លួនគាត់បានជាប់ឃុំឃាំងនៅក្នុងជំរំលត់ដំមួយ ហើយនិងនៅកន្លែងផ្សេងៗជាបន្តបន្ទាប់មកទៀត។

#### *ក.២.ក. ក-១៥*

សាក្សី **អុង ថុងហឿង** បានបញ្ជាក់ដោយយល់ស្របចំពោះការរៀបរាប់យ៉ាងលម្អិតស្តីពី **ក-១៥** ដែលគាត់បានសរសេរក្នុងសៀវភៅរបស់គាត់៖

> *"អតីតវិទ្យាស្ថានមិត្តភាពកម្ពុជា-សូវៀត គឺថាត្រូវបានកែប្រែទៅជាអង្គភាពមួយសម្រាប់អ្នកមកពីបរទេស ដូចជាយើងខ្ញុំដែលគេហៅថា ក-១៥ គឺគេត្រូវបានរៀបចំបម្រុងទុកសម្រាប់ឲ្យបញ្ញវន្តស្នាក់នៅ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា។"*

គាត់បានចងចាំថា មានបុគ្គលម្នាក់ឈ្មោះ **ភូមិ** ជាអ្នកកាន់កាប់ **ក-១៥**។ ជាងនេះទៅទៀត គាត់បានដឹងពីការសន្និដ្ឋានរបស់គាត់ថា គណៈមជ្ឈិមបានគ្រប់គ្រង **ក-១៥** ដោយផ្ទាល់ គឺផ្អែកទៅ

លើការសង្កេតរបស់មនុស្សផ្សេងៗគ្នាជាច្រើន ដែលគាត់បានរកឃើញនៅពេលដែលគាត់បានចាប់ផ្តើមស្រាវជ្រាវសម្រាប់សរសេរសៀវភៅរបស់គាត់។

### *ក.២.ខ. បឹងត្របែក (ប-៣២)*

សាក្សីបាននិយាយដដែលៗថា គាត់បានស្នាក់នៅក្នុងបឹងត្របែកចំនួនពីរដង គឺលើកទីមួយក្នុងឆ្នាំ១៩៧៦ ហើយលើកបន្ទាប់ នៅចុងឆ្នាំ១៩៧៨។ គាត់ចាំបានថា ស្ថានភាពលើកទីមួយមិនសូវជាធ្ងន់ធ្ងរដូចក្នុងអំឡុងពេលលើកទីពីររបស់គាត់នោះទេ ដោយសារតែវិន័យមិនសូវជាតឹងរឹង ហើយមានអាហារគ្រប់គ្រាន់ទៀតផង។ មេធាវី **កាណាវ៉ាស** បានព្យាយាមរកការបញ្ជាក់ពីអត្តសញ្ញាណរបស់ "**ជាប**" ដែលសាក្សី **អុង ថុងហឿង** បានដាក់ឈ្មោះក្នុងសៀវភៅរបស់គាត់ ថាជាបុគ្គលដែលបានមកជាមួយគាត់ និងជនមាតុភូមិនិវត្តន៍ផ្សេងទៀតទៅកាន់ **បឹងត្របែក** ក្នុងឆ្នាំ ១៩៧៨ តាមការបង្គាប់បញ្ជារបស់លោក **អៀង សារី**។ សាក្សីបានរៀបរាប់ពី **ជាប** ថាជាជំនួយការជិតស្និទ្ធរបស់លោក **សូ ហុង** ហើយគាត់បានទទួលស្គាល់ថា គាត់មិនសូវច្បាស់នឹងឈ្មោះនេះទេ ដោយសារតែគាត់បានជួប **ជាប** បានតែ២ដងគត់។ គាត់បានសុខចិត្តទទួលស្គាល់ថា គាត់ប្រហែលជាបានស្តាប់ច្រឡំ ហើយឈ្មោះជំនួយការហ្នឹង អាចជា **ជាម** ។

សាក្សី **អុង ថុងហឿង** ក៏បានអះអាងផងដែរថា លោក **ហោ ណាំហុង**[2] ត្រូវបានតែងតាំងជា "មេក្រុម" នៅ **ប-៣២** ចំនួនពីរដង។ គាត់បានបញ្ជាក់ថា គាត់បានមានវត្តមាននៅពេលដែលលោក **អៀង សារី** បានតែងតាំងលោក **ហោ ណាំហុង** នៅលើកទីពីរ។ ពេលនោះ លោក **អៀង សារី** បានធានាចំពោះពួកគេថា "ប្រទេសកម្ពុជាកំពុងមានបញ្ហាខ្លាំងជាមួយវៀតណាម ហើយនៅទីបំផុតកម្ពុជានឹងអាចមានជ័យជម្នះ។"

## *ក.៣. តួនាទីរបស់ជនជាប់ចោទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ*

សាក្សី បានស្គាល់លោក **អៀង សារី** ជារដ្ឋមន្ត្រីក្រសួងការបរទេស ហើយបានអះអាងថាជនជាប់ចោទរូបនេះ បានមានវត្តមានក្នុងពេលតែងតាំង "មេក្រុម" នៃ **ប-៣០** និង **ប-៣២** នៅក្នុងបឹងត្របែក។

ទាក់ទងនឹងជនជាប់ចោទលោក **ខៀវ សំផន** សាក្សី **អុង ថុងហឿង** បានអះអាងថា គាត់និងប្រពន្ធរបស់គាត់មិនដែលបានឃើញប្រធានគណៈប្រធានរដ្ឋមកកាន់បឹងត្របែកនោះទេ។ ទោះបីជាយ៉ាងនេះក្តី គាត់បាននិយាយសំដៅពីលោក **ខៀវ សំផន** ក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា ***ខ្ញុំជឿខ្មែរក្រហម*** ។ ក្នុងកថាខណ្ឌមួយ គាត់បានសរសេរថា អតីតសហការីនៅក្នុងវង់ម៉ាក្ស-ឡេនីន បានរៀបរាប់ពីលោក **ខៀវ សំផន** ថា "គាត់ (លោក **ខៀវ សំផន**) ធ្វើតែតាមគេ ហើយគាត់យល់ថាថ្នាក់លើធ្វើអ្វីក៏ត្រូវរហូត។" គាត់ក៏បានសរសេរផងដែរថា មានម្នាក់ឈ្មោះ **ប៊ុនរឿន** បានថ្លែងប្រាប់ថា លោក **ខៀវ សំផន** គឺ "...តាមខ្ញុំដឹងមក គាត់ (**ខៀវ សំផន**) មិនមែនទាំងជាសមាជិកមជ្ឈិមនៃបក្សកុម្មុយ នីស្តកម្ពុជាផងនោះទេ។ គាត់គ្រាន់តែជា មនុស្សទី៨ នៅក្នុងជួរបក្សប៉ុណ្ណោះ។" ជាង

នេះទៅទៀត សាក្សី **អុង ថុងហឿង** បានសរសេររៀបរាប់ពីកិច្ចប្រជុំមួយក្នុងមហាស្របចតុមុខ ដែលតាមឲ្យដឹងមក មានលោក **ប៉ុល ពត** ជាអធិបតី ដោយគាត់បាននិយាយដូចខាងក្រោមថា៖

> *...មិត្តភក្តិខ្ញុំបានទៅឃើញលោក **ខៀវ សំផន** ហើយបាននិយាយថា ពេលជុំគ្នាទាំងអស់ លោក **ខៀវ សំផន** មក ហើយគាត់បានឈរដូចគេដូចឯងអីចឹង អត់មានពីណាទទួលគាត់ ឬទុកកៅអីជូនគាត់ទេ។ ហើយដល់ដូច្នេះ អ្នកមកពីបរទេសទាំងអស់ហ្នឹងក៏ចាប់អារម្មណ៍ថា ចុះ! បើគាត់ប្រមុខរដ្ឋមាននាទីជាប្រមុខរដ្ឋអីចឹង គាត់មកអីចឹង វាដូចគ្មានអ្នកណាឃើញគាត់ -- គ្មានអ្នកណាចាំទទួលគាត់?*

### *ក.៤. ការងារនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង*

សាក្សីបានអះអាងថា អស់រយៈពេលប្រហែលជាពីរខែក្នុងឆ្នាំ១៩៧៩ គាត់បានធ្វើការជាអ្នកចងក្រងឯកសារក្នុងទួលស្លែង ដែលជាអតីតមន្ទីរសន្តិសុខ **ស-២១**។ មេធាវី **កាណាវ៉ាស** បានសុំឲ្យគាត់ធ្វើការបញ្ជាក់ពីអ្វីដែលនាំឲ្យគាត់មកធ្វើការនៅ **ស-២១** ៖ ថាតើគាត់បានឃើញចម្លើយសារភាពដែលយកមកខ្ចប់អាហារ ឬថាតើគាត់បានជួបអ្នកណាម្នាក់ ដែលសុំគាត់ឲ្យធ្វើការនៅ **ស-២១** នេះ ។ សាក្សី **អុង ថុងហឿង** បានពន្យល់ដូចខាងក្រោមថា៖

> *ខ្ញុំនៅផ្សារទួលទំពូង ខ្ញុំបានទិញចេកចៀន ហើយខ្ញុំឃើញឈ្មោះមិត្តខ្ញុំម្នាក់ ដែលខ្ញុំស្គាល់គាត់ឈ្មោះ គឺឈ្មោះ **កុល ដូរាធី**។ ហើយដូច្នេះ ដល់ខ្ញុំឃើញដូច្នេះ ខ្ញុំចង់ដឹងថាប្រភពដែលក្រដាសនោះមកពីណា ហើយខ្ញុំក៏បានសួរគេទៅគេថា មកពីទួលស្លែង។ ដូច្នេះ ដោយមូលហេតុធំ ខ្ញុំចង់ដឹងតើអ្វីទៅដែលប្រភពហ្នឹងចេញពីណាមក? ហើយវាយ៉ាងម៉េចរឿងអស់ហ្នឹង? កាលណោះ ខ្ញុំមិនដឹងថា ខ្ញុំអត់មានការចាប់អារម្មណ៍ថាមានអេសវ៉ាំងតេអង ឬទួលស្លែង នោះយ៉ាងម៉េចទេ។*

គាត់ចងចាំបន្ថែមថា នៅដែលពេលគាត់បានមកដល់ **ស-២១** គាត់ត្រូវបានណែនាំទៅកាន់មនុស្សម្នាក់ដែលគ្រប់គ្រងទីនោះ ហើយបន្ទាប់មក គាត់បានដឹងថា **ស-២១** ត្រូវការមនុស្ស "ធ្វើការក្នុងប័ណ្ណសារដ្ឋាន ដោយសារតែវាជាអំឡុងពេលដែលគេបានចាប់ផ្តើមរៀបចំតុលាការប្រជាជន។" ដូច្នេះ នៅពេលកំពុងធ្វើការនៅ **ស-២១** គាត់បានធ្វើការពាក់ព័ន្ធនឹងការរៀបចំឯកសារ និងបកប្រែចម្លើយសារភាពទាំងនោះទៅជាភាសាបារាំង ដើម្បីត្រៀមសម្រាប់ការជំនុំជម្រះក្តីរបស់ **ប៉ុល ពត** និង **អៀង សារី** ដោយកំបាំងមុខក្នុងខែសីហា ឆ្នាំ១៩៧៩។

### *ក.៥. បទសម្ភាសន៍ជាមួយលោក ស្ទីវ ហេដឌ័រ និងការងារជាមួយអ្នកស្រាវជ្រាវផ្សេងទៀត*

យោងតាមសាក្សី **អុង ថុងហឿង** ក្នុងខែកញ្ញា ឆ្នាំ១៩៧៩ គាត់បានទៅជំរំជនភៀសខ្លួន **ខៅអ៊ីដាង** ក្នុងប្រទេសថៃ ជាទីកន្លែងដែលគាត់ត្រូវបានសម្ភាសដោយលោកបណ្ឌិត **ស្ទីវ ហេដឌ័រ** ។ សាក្សីបាននិយាយថា ពួកគាត់បានជួបគ្នាបានប៉ុន្មានដងដែរ ក៏ប៉ុន្តែគាត់មិនអាចនឹកឃើញឡើងវិញថាតើគាត់បានបង្ហាញកំណត់ហេតុរបស់គាត់ទៅកាន់លោក **ហេដឌ័រ** ដែរឬទេ?

នៅដែលពេលប្រឈមមុខនឹងកថាខណ្ឌជាច្រើន ដកស្រង់ចេញពីកំណត់ហេតុសម្ភាសន៍របស់លោក **ហេងឌុំរ** បានធ្វើជាមួយគាត់ និងលោក **សួយ គីមហុង** សាក្សីបានបដិសេធទទួលស្គាល់ចម្លើយដែលគាត់បានធ្វើនោះ ហើយបាននិយាយថា "ខ្ញុំមិនអាចចងចាំសេចក្ដីលម្អិតនូវអ្វីដែលខ្ញុំបាននិយាយទៅកាន់គាត់ (លោក **ហេងឌុំរ**)។" គាត់បានបន្តថា "ខ្ញុំមិនអាចនិយាយអ្វីដែលគាត់ (លោក **ហេងឌុំរ**) ថតចម្លង ឬអ្វីដែលគាត់បានកត់ត្រា ខ្ញុំមិនបានអានកំណត់ហេតុទាំងហ្នឹងឡើយ។" សាក្សី **អុង ថុងហឿង** ក៏បានបដិសេធផ្នែកមួយនៃបទសម្ភាសន៍ដែលធ្វើឡើយដោយលោក **ហេងឌុំរ** ដែលនិយាយថា គាត់ជាសមាជិកនៃគណៈមជ្ឈិមរណសិរ្សរបស់លោក **ហេង សំរិន** ដោយបាននិយាយបដិសេធថា គាត់មិនដែលបានចូលជាសមាជិកនៃរណសិរ្សនេះឡើយ។

នៅពេលគាត់បានត្រឡប់មកពីប្រទេសបារាំងវិញក្នុងឆ្នាំ១៩៨០ គាត់បានធ្វើការជាមួយអ្នកសិក្សាជាច្រើន ដូចជា **ឡោរា សាមម័រ** (Laura Summers) ជាដើម ដើម្បីបកប្រែឯកសារ **ស-២១** ។

### *ក.៦. អាកប្បកិរិយា និងភាពគួរឲ្យជឿជាក់*

សាក្សី **អុង ថុងហឿង** ជាសាក្សីមួយក្នុងចំណោមសាក្សីដំបូងបានមកផ្ដល់សក្ខីកម្ម ដែលមិនមែនជាអ្នកជំនាញ សាក្សីផ្ទៃក្នុង ឬក៏ជាដើមបណ្ដឹងរដ្ឋប្បវេណីឡើយ តាមជាក់ស្ដែង គាត់បានផ្ដល់សក្ខីកម្ម ប្រកបដោយភាពឥតលាក់លៀម និងភាពស្មោះត្រង់ នៅចំពោះមុខអង្គជំនុំជម្រះ។ នៅចំពោះមុខការសួរចម្រាញ់យ៉ាងប្រយ័ត្នដោយក្រុមការពារក្ដី គាត់បានបដិសេធក្នុងការបញ្ជាក់ថា តើគាត់បានធ្វើសេចក្ដីថ្លែងការណ៍ដែលលោក **ហេងឌុំរ** បានចាត់ទុកថាជារបស់គាត់ដែរឬអត់? ដូច្នេះវានៅតែមិនច្បាស់ថា តើសាក្សីរូបនេះជាប្រភពនៃសេចក្ដីថ្លែងការណ៍ ដែលលោក **ហេងឌុំរ** បានដកស្រង់ចេញពីបទសម្ភាសន៍រួមគ្នាជាមួយសាក្សី ហើយនិងលោក **សួយ គីម**។ សាក្សី **អុង ថុងហឿង** ក៏បានដេញដោលផងដែរពីបទសម្ភាសន៍ ដែលគាត់បានផ្ដល់ឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងឆ្នាំ២០០៧ ដោយគាត់បានរៀបរាប់ថា "មានការយល់ច្រឡំខ្លាំង"។ គាត់បាននិយាយថា គាត់មិនអាចចាំថាអ្នកណាដែលបានធ្វើបទសម្ភាសន៍ជាមួយគាត់ ហើយគាត់បានបន្ថែមថា "ដូច្នេះបានខ្ញុំៗចេះតែឆ្ងល់ហើយឆ្ងល់ទៀតខ្ញុំមើលឡើងវិញម្ដងហើយម្ដងទៀត ហេតុដូចម្ដេចបានជាខ្ញុំនិយាយអ៊ីចឹងហើយគេដាក់ថា -- គេសរសេរថាខ្ញុំនិយាយអ៊ីចឹង ដូច្នេះវាអត់ឈរលើការពិតទេបាទ។ អ៊ីចឹងបានឆ្នាំ២០០៨ ខ្ញុំបញ្ជាក់ហើយបញ្ជាក់ទៀតថា ខ្ញុំអត់ទទួលស្គាល់ឯកសារនេះទេ។" គាត់គ្រាន់តែបានដឹងពីបទសម្ភាសន៍ ដែលគាត់បានផ្ដល់ឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេតនៅឆ្នាំ២០០៨ ហើយនិយាយថា "ក្នុងនាមតុលាការ គឺខ្ញុំបានចាំច្បាស់លើកទី១ ដែលខ្ញុំបានផ្ដល់បទសម្ភាសន៍នៅក្នុងឆ្នាំ២០០៨។"

## ខ. សក្ខីកម្មរបស់សាក្សី សួង ស៊ីគឿន

សប្តាហ៍នេះ គឺជាវេនរបស់ក្រុមការពារក្តីនៅក្នុងការសួរដេញដោលសាក្សី **សួង ស៊ីគឿន**។ មេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទលោក **ខៀវ សំផន** គឺលោកស្រី **អង់តា ហ្គីសសេ** បានផ្តោតសំណួរពាក់ព័ន្ធនឹងតួនាទីកូនក្តីរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង គោលការណ៍រក្សាការសម្ងាត់។ មេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទលោក **នួន ជា** គឺលោក **ហ្សាស្តើ ប៉ៅ** បានសួរសំណួរស្តីពីទំនាក់ទំនងរបស់មន្ត្រីរដ្ឋាភិបាលដែលកំពុងកាន់មុខតំណែង ទៅនឹងរណសិរ្សរួបរួមជាតិកម្ពុជា រដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងក្រសួងការបរទេស។ ម្យ៉ាងវិញទៀត មេធាវី **កាណាវ៉ាស** បានសួរដេញដោលពីទំនាក់ទំនងរបស់សាក្សី **សួង ស៊ីគឿន** ជាមួយនឹងសាក្សីផ្សេងទៀត មុនពេលមកផ្តល់សក្ខីកម្មរបស់គាត់ ពីរចនាសម្ព័ន្ធក្រសួងការបរទេស ហើយនិងតួនាទីដែលកាន់ដោយ **ប៉ុល ពត** និង **អៀង សារី** ក្នុងរបបនេះ។

### *ខ.១. រចនាសម្ព័ន្ធរដ្ឋបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ*

សាក្សី បានផ្តល់សក្ខីកម្មស្តីពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ទាក់ទងនឹងឋានានុក្រមបញ្ជានៃរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់ក៏បានផ្តល់ព័ត៌មានលម្អិតផងដែរ ស្តីពីរចនាសម្ព័ន្ធនៃក្រសួងការបរទេស។

#### *ខ.១.ក. ឋានានុក្រមបញ្ជា និងលោក ប៉ុល ពត*

សាក្សី **សួង ស៊ីគឿន** បានរៀបរាប់ពីលោក **ប៉ុល ពត** ថា "អ្វីៗគឺគាត់ហ្មត់ចត់ណាស់... គាត់គិតគូរតាំងពីអាការបន្តិចបន្តួច" នៃកិច្ចការ ដែលដកស្រង់ចេញពីអត្ថបទនៃការផ្សព្វផ្សាយវិទ្យុរហូតដល់ *ម៉ឺនុយ* មុខម្ហូបអាហារទទួលភ្ញៀវទៀតផង។ គាត់បាននិយាយដដែលៗថា ទោះបីជាលោក **អៀង សារី** ជាអ្នកស្នើឲ្យតែងតាំងគាត់ទៅក្រសួងការបរទេសក៏ដោយ ក៏លោក **ប៉ុល ពត** ជាអ្នកសម្រេចចិត្តចុងក្រោយផងដែរ។ គាត់មិនបានជឿជាក់ថា គណៈអចិន្ត្រៃយ៍ ឬគណៈមជ្ឈិម បានរួមចំណែកនៅក្នុងការតែងតាំងគាត់នោះទេ ដោយសារតែសមាជិកគណៈកម្មាធិការ ដូចជា លោក **នួន ជា** បានមិនស្គាល់គាត់ច្បាស់ផង។ នៅពេលដែលមេធាវី **កាណាវ៉ាស** បានសួរពីភាពខុសគ្នារវាងលោក **ប៉ុល ពត** និង "មជ្ឈិម" សាក្សីបានបង្ហើបប្រាប់ថា "តាមខ្ញុំមើលទៅ តែមួយទេបាទ ដែលខ្ញុំនិយាយថា៖ មជ្ឈិមហ្នឹង គឺថាគេហៅថាកម្មាភិបាលដែលក្រោមការគ្រប់គ្រងរបស់មជ្ឈិម។ ហើយមជ្ឈិមហ្នឹង គឺ **ប៉ុល ពត** ហើយបាទ។"

សាក្សីបាននិយាយឡើងវិញថាលោក **ប៉ុល ពត** បានតែងតាំងគាត់ឲ្យធ្វើជានាយកព័ត៌មាននៃទីភ្នាក់ងារសារព័ត៌មានកម្ពុជា នៅឆ្នាំ១៩៧៨[3] ដែលតំណែងមួយនេះតម្រូវឲ្យរាយការណ៍ដោយផ្ទាល់ទៅបងធំទី១[4]។ គាត់បានបង្ហាញថា ទាំង **ប៉ុល ពត** និង **នួន ជា**[5] មានសិទ្ធិអំណាចក្នុងការចាត់ការងារឲ្យសមាជិកបក្ស ដោយមិនចាំបាច់ឆ្លងកាត់មេផ្ទាល់របស់ពួកគេទេ ដូចក្នុងករណីរបស់គាត់ ដោយមិនចាំបាច់ឆ្លងលោក **អៀង សារី** នោះទេ។ យោងតាមសាក្សី គាត់មិនមានកាតព្វកិច្ចពិភាក្សា ឬរាយការណ៍ទៅឲ្យលោក **អៀង សារី** នៅពេលដែលគាត់ធ្វើការងារណាដែលបញ្ជាដោយ **ប៉ុល ពត**

ផ្ទាល់។ គាត់បានដកស្រង់គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដើម្បីសង្កត់ធ្ងន់លើចំណុចរបស់គាត់៖ “ខាងក្រោមត្រូវគោរពខាងលើ ភាគតិចត្រូវគោរពភាគច្រើនបាទ”។ គាត់ក៏បានពន្យល់ថា គោលការណ៍នេះមិនត្រឹមតែបានអនុវត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវបានអនុវត្តក្រោយការរំលំនៃរបបនេះផងដែរ។

### *ខ.១.ខ. ក្រសួងការបរទេស*

ដូចដែលសាក្សីបាននិយាយកាលពីសប្តាហ៍មុន ក្រសួងការបរទេស ក៏ត្រូវបានហៅថាជា **ប-១** ផងដែរ ដែលបានបែងចែកជាពីរផ្នែក៖ ផ្នែកការិយាល័យ និងផ្នែកមន្ទីរ។[6] ផ្នែកការិយាល័យទទួលខុសត្រូវខាងបង្កបង្កើនផល និងសន្តិសុខ រីឯផ្នែកមន្ទីរវិញ ទទួលបន្ទុកខាងទំនាក់ទំនងការទូត។ ក្នុងបរិវេណ **ប-១** មានអគារមួយចំនួនប្រើប្រាស់ជាការិយាល័យ អគារវីឡាស្នាក់នៅមួយជាន់ និងកន្លែងស្នាក់នៅរបស់កម្មាភិបាល និងយុទ្ធជន។ គាត់បានទទួលស្គាល់ពីឋានៈរបស់គាត់ដែលជានាយកសារព័ត៌មាន និងឃោសនាការនៃក្រសួងការបរទេស និងជាប្រធានរៀបចំបញ្ជីឈ្មោះកម្មាភិបាល និងមុខតំណែង នៅក្នុងក្រសួងការបរទេស ដែលគាត់ផ្តល់ក្នុងសេចក្តីថ្លែងការណ៍របស់គាត់ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងឆ្នាំ២០០៧។

**លោក អៀង សារី** ៖ សាក្សីបានស្គាល់លោក **អៀង សារី** ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស និងជាថ្នាក់ដឹកនាំក្រសួងការបរទេស។ ជាងនេះទៅទៀត ជនជាប់ចោទបានបម្រើការងារជាថ្នាក់ដឹកនាំនៃអង្គភាពនយោបាយទូទៅរបស់ក្រសួងការបរទេស ដែលមានបញ្ញវន្តដូចជា **ឱក សុគន្ធ, ជួន ប្រសិទ្ធិ** និង **គាត ឈន់** ជាសមាជិក។ សាក្សី **សួង ស៊ីគឿន** បានរៀបរាប់ពីលោក **អៀង សារី** ជាមនុស្សម្នាក់ដែល “ស្តាប់មតិអ្នកដទៃ ហើយគាត់អំពាវនាវឲ្យសហការីរបស់គាត់ហ្នឹងមានមតិលើគ្រប់បញ្ហា ហើយកុំឲ្យមានការបារម្ភ ព្រួយបារម្ភ ឬក៏ខ្លាចរំពៃអីឲ្យមានមតិ”។ គាត់បានបន្ថែមទៀតថាលោក **អៀង សារី** បានអប់រំពួកគេឲ្យទទួលខុសត្រូវលើតួនាទីរបស់ពួកគេ ហើយនិងបញ្ចេញគំនិតរបស់ពួកគេ ព្រោះថាពួកគេសុទ្ធតែនៅជិតថ្នាក់ដឹកនាំ។

**“ក្រុមស្នូល” នៃក្រសួងការបរទេស** ៖ ក្នុងសៀវភៅរបស់លោក **សួង ស៊ីគឿន** ដែលមានចំណងជើងថា *ដំណើរផ្សងព្រេងរបស់បញ្ញវន្តខ្មែរក្រហម* គាត់បានបង្ហាញថា ខ្លួនគាត់ លោក **គាត ឈន់** និងម្នាក់ឈ្មោះ **បុរី** បាននាំគ្នាបង្កើត **“ក្រុមស្នូល”** ដែលក្រោយមកបង្កើតបានជាក្រសួងការបរទេសនេះឡើង។ គាត់បានពន្យល់ថា **អៀង សារី** បានចាត់តាំងពួកគាត់ឲ្យប្រមូល និងវិភាគព័ត៌មានពីវិទ្យុផ្សព្វផ្សាយបរទេសស្តីពីការតស៊ូក្នុងប្រទេសកម្ពុជា និងមជ្ឈដ្ឋានអន្តរជាតិនៅពេលនោះផងដែរ។ សាក្សីចាំបានថា លោក **គាត ឈន់** ដែលជាមេក្រុមត្រូវមានភារកិច្ចធ្វើរបាយការណ៍ទៅ **អៀង សារី** ជារៀងរាល់ខែ។ គាត់ពន្យល់ថា របាយការណ៍របស់ពួកគាត់ បានជួយថ្នាក់ដឹកនាំក្នុងការបង្កើតគោលនយោបាយបរទេសនៃកម្ពុជាប្រជាធិបតេយ្យដែលទើបតែបង្កើតថ្មីៗហ្នឹង។

**លោក សូ ហុង** ៖ យោងតាមសាក្សី **សួង ស៊ីគឿន** លោក **សូ ហុង**[7] គឺជាលេខាទូទៅនៃក្រសួងការបរទេស ហើយក៏ជាមនុស្សដៃស្តាំរបស់លោក **អៀង សារី** ផងដែរ។ តាមឲ្យដឹងមក តួនាទីលេខាទូទៅរបស់គាត់ មិនមានអ្វីធ្វើទាក់ទងនឹងកិច្ចការបរទេសនោះទេ ពីព្រោះគាត់ធ្វើតែការងារបង្ក

បង្កើនផល និងសន្តិសុខ។ លោក **សូ ហុង** ជាមួយនឹងកម្មាភិបាលថ្នាក់ក្រោមគាត់ គឺ **ភី ភួន** បាន ទទួលបន្ទុកលើសន្តិសុខរបស់ភ្ញៀវបរទេស។

**លោក ភី ភួន** ៖ សាក្សីបានថ្លែងថា ប្រធានផ្នែកសន្តិសុខ ឬកងការពារ លោក **ភី ភួន**[៩] គឺជាអ្នកទទួលបន្ទុកការពារស្ថានទូត និងអ្នកការទូតនៅក្នុងប្រទេសកម្ពុជា។ គាត់បានពន្យល់ថា គាត់មិនបានដឹងពីទំនាក់ទំនងការងាររបស់ **ភី ភួន** ជាមួយនឹង **ប៉ង់** មុនឆ្នាំ១៩៧៥ ដោយសារតែគាត់មិនទាន់បានជួប **ភី ភួន នៅ**ពេលនោះទេ។

**អ្នកស្រី សួរ សែ** ៖ យោងទៅតាមសាក្សីរូបនេះ អ្នកស្រី **សួរ សែ** គ្រាន់តែបានអនុវត្តតួនាទីរបស់គាត់ជាលេខាសាខាបក្សក្នុងក្រសួងការបរទេស ទោះបីជាគាត់បានមានតួនាទីពីរផ្សេងទៀតក៏ដោយ៖ ជាប្រធានលេខាធិការដ្ឋាន និងប្រធានផ្នែកពិធីការ។ ក៏ប៉ុន្តែ ទោះបីជាគាត់កាន់តួនាទីបីក៏ដោយ តាមឲ្យដឹងមក គាត់ក៏មិនបានមានសិទ្ធិអំណាចអ្វីនោះទេ។ តួនាទីសំខាន់របស់គាត់ គឺដឹកនាំកិច្ចប្រជុំ ហើយរាយការណ៍ទៅ **សូ ហុង** ឬ **អៀង សារី**។ កិច្ចការរបស់គាត់នៅក្នុងផ្នែកពិធីការ និងលេខាធិការដ្ឋាន គឺរៀបចំឯកសារ និងរបស់របរសម្រាប់ទទួលភ្ញៀវ។ សាក្សី **សួង ស៊ីគឿន** ក៏បាននិយាយផងដែរថា គាត់បានដាក់ផលិតផលសម្រេចរបស់គាត់ទៅ **ប៉ុល ពត** តាមរយៈអ្នកស្រី **សួរ សែ** ផងដែរ។

### *ខ.២. តួនាទីរបស់ជនជាប់ចោទលោក ខៀវ សំផន នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា*

សាក្សី **សួង ស៊ីគឿន** បានផ្តល់សក្ខីកម្មថា លោក **វ៉ាន់ រិទ្ធ** ជាអតីតប្រធានគណៈកម្មាធិការពាណិជ្ជកម្មបានប្រាប់គាត់ថា ជនជាប់ចោទ **ខៀវ សំផន** គឺជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបរទេសនៃកម្ពុជាប្រជាធិបតេយ្យ និងជាអ្នកទទួលខុសត្រូវទិញថ្នាំពេទ្យព្រមទាំង គ្រឿងបន្លាស់ម៉ាស៊ីនផ្សេងៗពីបរទេស។ លោកស្រី **អាន់តា ហ្គីសសេ** បានស្នើទៅសាក្សីដើម្បីសុំការបញ្ជាក់ ចំពោះការលើកឡើងដែលថា "តួនាទីរបស់លោក **ខៀវ សំផន** មានត្រឹមតែឈ្មោះ" ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ លោក **សួង ស៊ីគឿន** បានឆ្លើយថាជនជាប់ចោទ **ខៀវ សំផន** "បានប្រគល់ខ្លួនរបស់គាត់ទៅឲ្យបក្ស" និងថា គាត់មិនដែលបានទាមទារតួនាទីអ្វីពីបក្សទេ គឺអាស្រ័យលើបក្សវិនិច្ឆ័យថា គាត់អាចបំពេញភារកិច្ចបានប្រសើរកន្លែងណា អាចចាត់ឲ្យគាត់ធ្វើការតាមជំនាញនោះបាន។[៩] សាក្សីក៏បានបន្ថែមទៀតថា "ខ្ញុំបានរស់នៅជាមួយគាត់ និង **ប៉ុល ពត** គឺនៅឆ្នាំ១៩៨១ និង ឆ្នាំ១៩៨២ ហើយខ្ញុំអាចសង្កេតឃើញថា លោក **ខៀវ សំផន** មិនមានតួនាទីអ្វីនោះទេ ក្នុងការបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគីរបស់បក្សនោះទេ គឺ **ប៉ុល ពត** ជាអ្នកសម្រេចទាំងអស់"។ សាក្សី **សួង ស៊ីគឿន** បានមានប្រសាសន៍ថា មានឧទាហរណ៍ជាក់ស្តែងមួយ គឺក្នុងឆ្នាំ១៩៨១ **ប៉ុល ពត** បានចាត់តាំងគាត់ដោយផ្ទាល់ ឲ្យធ្វើជាអ្នកតំណាងកម្ពុជាប្រជាធិបតេយ្យ ដើម្បីធ្វើការចរចាបង្កើតរដ្ឋាភិបាលត្រីភាគី និងមិនបានប្រគល់នាទីនេះទៅឲ្យលោក **ខៀវ សំផន** ឡើយ ទោះបីជាពួកគាត់ កំពុងតែមានវត្តមានក្នុងការប្រជុំគ្នាមួយក៏ដោយ ។[10]

## ខ.៣. គោលការណ៍នៃការរក្សាការសម្ងាត់

យោងតាមសាក្សី **សួង ស៊ីគឿន** បានឲ្យដឹងថា គោលការណ៍នៃការរក្សាការសម្ងាត់ គឺជាគោលការណ៍ដ៏សំខាន់បំផុតនៃបក្សកុម្មុយនីស្តកម្ពុជា ដែលការប្រកាន់ខ្ជាប់នូវគោលការណ៍នេះ គឺស្មើនឹងការអាចធានាពីការទទួលជ័យជម្នះបានពាក់កណ្តាលដូច្នោះដែរ "ការរក្សាការសម្ងាត់ គឺមានន័យថា បដិវត្តន៍ឈ្នះបាន៥០ភាគរយ នេះជាគោលការណ៍"។ សាក្សីបានពន្យល់ថា ផ្អែកលើមាគ៌ាបក្ស ថ្នាក់ក្រោមមិនត្រូវលាក់ព័ត៌មានផ្សេងៗដល់អ្នកគ្រប់គ្រងផ្ទាល់របស់ពួកគេឡើយ ដើម្បីបង្ហាញពីភក្តីភាពរបស់ខ្លួនចំពោះបក្ស ប៉ុន្តែមេដឹកនាំផ្ទាល់ទាំងនោះ អាចរក្សាទុកព័ត៌មានពីថ្នាក់ក្រោមបង្គាប់របស់ខ្លួន ក្នុងក្របខ័ណ្ឌនៃការទទួលខុសត្រូវរបស់ពួកគេបាន ។ នៅពេលចោទសួរពីការមិនបានដឹងឮនូវកាតព្វកិច្ចរបស់បុគ្គលឈ្មោះ **ភី ភួន** នៅការិយាល័យ ប-១ សាក្សី **សួង ស៊ីគឿន** បានឆ្លើយតបថា ខ្លួនមិនបានដឹងឮរឿងរ៉ាវអ្វីពីបុគ្គលផ្សេងៗឡើយ ដោយលើកហេតុផលថា "អាហ្នឹងអនុវត្តចំពោះគ្រប់គ្នាបាទ ។ យើងមិនចង់ដឹងឮព័ត៌មានពីគេ ហើយគេក៏មិនមានសិទ្ធិអី មិនមានការចាំបាច់អី ផ្តល់ព័ត៌មានដល់យើងក្រៅក្របខ័ណ្ឌនៃភារកិច្ចដែលយើងបំពេញទេបាទ" ។ ប្រសិនបើគាត់ហ៊ានសួរនាំពីភារកិច្ចទទួលខុសត្រូវរបស់បុគ្គលផ្សេង ឬពីបុគ្គលឈ្មោះ **ភី ភួន** ផ្ទាល់ គឺមានន័យថា គាត់បំពារបំពាននូវគោលការណ៍នេះ។

## ខ.៤. ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ

សាក្សីបានបង្ហាញឲ្យដឹងថា លោកបានមកដល់ទីក្រុងភ្នំពេញនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៥។ លោក **សួង ស៊ីគឿន** បានបន្ថែមទៀតថា ទីក្រុងភ្នំពេញពេលនោះ មានសភាពស្ងាត់ជ្រងំមិនកុះករដូចធម្មតាទេ ហើយគាត់ឃើញមានតែក្រុមនារីធ្វើការងារលីសែង និងដឹកជញ្ជូនអង្ករចេញពីកបាល់ឡើងមកច្រាំងនៅកំពង់ផែនៃទីក្រុងភ្នំពេញតែប៉ុណ្ណោះ។ សេចក្តីដកស្រង់ពីសៀវភៅដែលមានចំណងជើងថា "ឆ្ងាយហួសពីជើងមេឃ" សរសេរដោយអតីតភរិយារបស់សាក្សីផ្ទាល់ ឈ្មោះលោកស្រី **ឡូរ៉ង់ ពិច** បានថ្លែងថា ក្រោយការរំដោះហើយភ្លាមៗ មានការស្រាវជ្រាវយ៉ាងហ្មត់ចត់រុករកក្រុមកម្លាំងយុទ្ធជនតស៊ូ ដែលនៅសេសសល់ខ្លះៗ និងបានសម្ងំលាក់ខ្លួននៅតាមទីតាំងសម្ងាត់នានានៅទីក្រុងភ្នំពេញ ។ យោងតាមអ្វីដែលមេធាវី **ហ្សាស្គី ប៉ៅ** បានអាននៅក្នុងបន្ទប់តុលាការ ខ្លឹមសារដកស្រង់មានដូចតទៅ៖ "ប៉ុន្មានអាទិត្យក្រោយមកនៃការរំដោះ គេនៅរកឃើញពួកយុទ្ធជនពួននៅតាមចន្លោះកន្លៀត... ពួកនេះបានលាក់ស្បៀងទុកនៅឡើយ។ អ្វីដែលធ្វើឲ្យយុទ្ធជនបានសើចសប្បាយនោះ គឺជាប្រការដែលគេឃើញជនរួមជាតិ (ក្រុមតស៊ូ) របស់ពួកគេ មានសាច់ឡើងស ជាដើមនោះ" ។ លោក **សួង ស៊ីគឿន** បានគូសបញ្ជាក់ថា លោក និងភរិយារបស់គាត់គ្រាន់តែបានឮព័ត៌មាននេះតពីយុទ្ធជនតែប៉ុណ្ណោះ ដែលពួកគេនិយាយតៗគ្នាយ៉ាងដូច្នេះ។ លោកបានបន្ថែមថា មានយុទ្ធជនមួយចំនួន និងជនស៊ីវិលខ្លះបានសម្ងំលាក់ខ្លួននៅតាមទីកន្លុកកន្លៀតតូចៗ ប៉ុន្តែមិនមានប្រជាជនច្រើនទេ ពោលគឺមានត្រឹមតែម្នាក់ ឬពីរនាក់តែប៉ុណ្ណោះ ។

## ខ.៥. *រណសិរ្សរួបរួមជាតិកម្ពុជា (FUNK)*

លោក **សួង ស៊ីគឿន** បានចង្អុលបង្ហាញថា រណសិរ្សរួបរួមជាតិកម្ពុជា គឺជាសម្ព័ន្ធភាពរវាងកម្លាំងនយោបាយដែលមាននិន្នាការប្លែកៗគ្នា ដើម្បីសម្រេចនូវគោលបំណងរួម ពោលគឺជាកម្លាំងស្នេហាជាតិទាំងមូល រួមមាន៖ កម្លាំងរបស់រាជានិយម កម្លាំងរបស់ពួកបក្សកុម្មុយនីស្តកម្ពុជា ហើយកម្លាំងស្នេហាជាតិ គឺជាកម្លាំងកណ្តាល។ បើទោះបីជាសាក្សីបានដឹងថា ព្រះអង្គម្ចាស់ **នរោត្តម សីហនុ** គឺជាមេដឹកនាំ និងជាអ្នកនាំពាក្យរបស់រណសិរ្សនេះក្តី ក៏ប៉ុន្តែយោងតាមសាក្សីបានឲ្យដឹងថា "ទីភ្នាក់ងារព័ត៌មានកម្ពុជា" គឺមិនមែនសម្តេចព្រះ **នរោត្តម សីហនុ** ហើយក៏មិនមែនរណសិរ្សនៅក្រៅប្រទេសជាអ្នកគ្រប់គ្រងដែរ។ គាត់បានប្រាកដក្នុងចិត្តថា គឺ "ផ្នែកតស៊ូនៅក្នុងប្រទេសជាអ្នកគ្រប់គ្រង" ពីព្រោះ មានសាររបស់ព្រះអង្គមួយចំនួនត្រូវបានគេដកស្រង់ដាក់ក្នុងព្រឹត្តិបត្រព័ត៌មានប្រចាំសប្តាហ៍របស់ទីភ្នាក់ងារព័ត៌មានមួយនេះ។ បើតាមការអះអាងរបស់សាក្សី លោក **អៀង សារី** គឺជា៖ *អ្នកតំណាងផ្នែកក្នុងប្រទេស ជាមួយរណសិរ្សនៅក្រៅប្រទេស ខណៈពេលដែលមានអ្នកកាន់កាប់ការិយាល័យនយោបាយ មានមុខងារទទួលបន្ទុកដោះស្រាយបញ្ហាពីកម្លាំងតស៊ូក្រៅប្រទេស* ។ សាក្សី **សួង ស៊ីគឿន** បានផ្តល់ឈ្មោះមន្ត្រីថ្នាក់ខ្ពស់របស់រណសិរ្សពីររូប គឺទីមួយ សម្តេច **ប៉ែន នុត** គឺជាប្រធានការិយាល័យរបស់រណសិរ្សរួបរួមជាតិកម្ពុជានៅក្រៅប្រទេស ចំណែកឯលោក **គាត ឈន់** គឺជាលេខាធិការនៃការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជា និងជារដ្ឋមន្ត្រីប្រតិភូរបស់នាយករដ្ឋមន្ត្រី ទទួលបន្ទុកផ្នែកបដិសណ្ឋារកិច្ច និងការប្រជុំធំៗមួយចំនួន ។

ឆ្លើយតបនឹងសំណួរសួរដោយមេធាវី **កាណាវ៉ាស** លោកសាក្សី **សួង ស៊ីគឿន** បានអះអាងយ៉ាងមុតមាំថា ដំណើរទស្សនកិច្ចរបស់សម្តេច **នរោត្តម សីហនុ** ជាមួយនឹងលោក **អៀង សារី** ទៅកាន់ទីក្រុងប៉ុយការ៉េស គឺនៅក្នុងឆ្នាំ១៩៧៣។ ព័ត៌មាននៃដំណើរទស្សនកិច្ចមួយនេះ គឺផ្ទុយគ្នាពីព័ត៌មានដែលទទួលបានពីប្រវត្តិវិទូ **ឌេវីដ ឆេនដ៍ល័រ** និងដើមបណ្តឹងរដ្ឋប្បវេណីលោក **អ៊ុង ចុងហៀង** ដែលធ្លាប់បានអះអាងថា ដំណើរទស្សនកិច្ចត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ១៩៧៤។ សាក្សីបានគូសបញ្ជាក់ថា នៅឆ្នាំ១៩៧៤ លោក **អៀង សារី** បានរួមក្នុងដំណើរទស្សនកិច្ចជាមួយគណៈប្រតិភូមួយក្រុមក្នុងទីក្រុងប៉ុយការ៉េស ដែលដឹកនាំដោយលោក **ខៀវ សំផន**។

## ខ.៦. *អត្តចរិត និង ភាពជឿជាក់*

លោក **សួង ស៊ីគឿន** បានផ្តល់សក្ខីកម្មប្រកបដោយភាពជឿជាក់ខ្ពស់ និងបានចូលរួមសហប្រតិបត្តិការឆ្លើយសំណួរស្ទើររាល់កិច្ចដំណើរការនីតិវិធី។ ទោះជាយ៉ាងណាក្តី លោកប្រែជាមានការប្រុងប្រយ័ត្ន ចំពោះការឆ្លើយតបទៅនឹងប្រធានបទជាក់លាក់មួយចំនួន ដោយសាក្សីបានស្នើសុំការណែនាំពីលោកប្រធានតុលាការ និងពីមេធាវីប្រឹក្សាក្តីផ្ទាល់ខ្លួនរបស់គាត់ ថាតើគាត់គួរតែឆ្លើយតបនឹងសំណួរមួយចំនួនដែលទាក់ទងទៅនឹងរដ្ឋាភិបាលបច្ចុប្បន្ននេះដែរឬទេ? [11] មានបញ្ហាមួយចំនួនត្រូវបានលើកឡើង ជាពិសេស អំពីទំនាក់ទំនងរបស់គាត់ជាមួយនឹងសាក្សីផ្សេងទៀត ក៏ដូចជាមានការសួរនាំផងដែរ ថាតើសាក្សី **សួង ស៊ីគឿន** បានតាមដានកិច្ចដំណើរការនីតិវិធីតុលាការតាមរយៈប្រព័ន្ធផ្សព្វផ្សាយឬយ៉ាងណា មុនពេលគាត់ចូលខ្លួនមកផ្តល់សក្ខីកម្មដោយផ្ទាល់ ដោយសារទង្វើនេះ

អាចជាកង្វល់ស្តីពីសុច្ចរិតភាពនៃការផ្តល់សក្ខីកម្មរបស់គាត់ ។ បញ្ហាទាំងនេះ ត្រូវបានជជែកពិភាក្សាយ៉ាងលម្អិតនៅក្នុង *ផ្នែកទី៣ (ខ)* ផ្នែកខាងក្រោមនៃរបាយការណ៍នេះ ។

## គ. សក្ខីកម្មរបស់ អ្នកស្រី ស សៀក

អ្នកស្រី **ស សៀក** ហៅក្រៅថា "**ស៊ីម**" បានកើតនៅឆ្នាំ១៩៥៦ នៅស្រុកព្រៃវែង និងខេត្តព្រៃវែង។ បច្ចុប្បន្ន អ្នកស្រី គឺជាកសិករម្នាក់នៅស្រុកសំឡូត ខេត្តបាត់ដំបង។ ការសួរដេញដោលដោយភាគីសហព្រះរាជអាជ្ញា គឺលោក **វេង ហ៊ត់** និងលោក **ថារិក អាប់ឌុលហាក់** បានផ្តោតទៅលើការជម្លៀសចុងក្រោយពីទីក្រុងភ្នំពេញ រចនាសម្ព័ន្ធរបស់ក្រសួងឃោសនាការ និងការទំនាក់ទំនងរវាង អ្នកស្រី **ស សៀក** ជាមួយមេដឹកនាំខ្មែរក្រហម។

### *គ.១. ចលនានៃរចនាសម្ព័ន្ធឃោសនាការ មុនកម្ពុជាប្រជាធិបតេយ្យ*

យោងតាមអ្នកស្រី **ស សៀក** មុនពេលដែលកម្ពុជាប្រជាធិបតេយ្យត្រូវបានបង្កើតឡើង អ្នកស្រី គឺជាសមាជិកម្នាក់នៃអង្គភាពសិល្បៈដែលគេស្គាល់ថាជាការិយាល័យ ស-៦ មានទីតាំងស្ថិតនៅខេត្តស្ទឹងត្រែង។ អង្គភាពសិល្បៈមាននាទីថតបទចម្រៀង ហើយផ្ញើទៅចាក់ផ្សាយតាមស្ថានីយវិទ្យុមួយនៅទីក្រុងហាណូយ ប្រទេសវៀតណាម។ ក្រៅពីការិយាល័យ ស-៦ នេះ ក៏មានការិយាល័យផ្សេងៗទៀតផងដែរ នៅក្នុងខេត្តស្ទឹងត្រែង រួមមានដូចជាការិយាល័យប-២០ ដែលទទួលខុសត្រូវក្នុងការចែកគ្រឿងឧបភោគបរិភោគដល់អង្គភាពតូចៗមួយចំនួនទៀតនៅក្នុងតំបន់ ចំណែកឯការិយាល័យ ក-១៨ វិញ គឺជាក្រុមស្ត្រីដេរប៉ាក់ ។

នៅពេលសួរអំពីស្ថានីយវិទ្យុចល័ត អ្នកស្រី **ស សៀក** បានគូសបញ្ជាក់ថា ដោយសារតែអ្នកស្រីមិនមែនជាសមាជិកនៃក្រុមស្ថានីយវិទ្យុនេះ អ្នកស្រីមិនបានដឹងថា រចនាសម្ព័ន្ធ និងបុគ្គលពាក់ព័ន្ធនឹងការងារនេះ ជានរណាខ្លះឡើយ។ ទោះជាយ៉ាងនេះក្តី អ្នកស្រីអាចត្រឹមតែនិយាយបានថា ការផ្សព្វផ្សាយរបស់ស្ថានីយផ្សាយចល័តទាំងនេះ គឺត្រូវបានធ្វើឡើងដើម្បីលើកទឹកចិត្ត និងបំផុសការឈឺចាប់ចំពោះការឈ្លានពានទឹកដី (កោះត្រល់) ក៏ដូចជាបង្កើនស្មារតីស្នេហាជាតិដល់យុទ្ធជននៅឯសមរភូមិ។

### *គ.២. ការ "រំដោះ" និង ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ*

អ្នកស្រី **ស សៀក** បានអះអាងថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មានការចាក់ផ្សាយតាមវិទ្យុ ដោយបានប្រកាសស្តីពីភាពជោគជ័យនៃការរំដោះទីក្រុងភ្នំពេញ។[12] នៅថ្ងៃដដែលនេះដែរ អង្គភាពសិល្បៈ បានចាប់ផ្តើមចេញដំណើរចេញពីខេត្តស្ទឹងត្រែងទៅកាន់ទីក្រុងភ្នំពេញ ជាមួយនឹងមេដឹកនាំនៃអង្គភាពនេះ គឺសមមិត្ត **ហ៊ូ នឹម** និង សមមិត្ត **ទីវ អុល** ជាជំនួយការ។ ឈានចូលដល់ទីក្រុងភ្នំពេញបានបួនថ្ងៃក្រោយមក អ្នកស្រី ព្រមទាំងសមាជិកផ្សេងទៀតដែលនៅសេសសល់ក្នុងអង្គភាពផ្នែកសិល្បៈនេះ បាននាំគ្នាធ្វើដំណើរទៅកាន់ពហុកីឡាដ្ឋានជាតិអូឡាំពិក ជាកន្លែងដែលអ្នកស្រីបានសង្កេតឃើញដូចតទៅ ៖

*...នាងខ្ញុំបានចូលមកនៅម្តុំស្ពាត ក៏ឃើញមានកងទ័ពស្រីប្រុស មានឃើញ ឧបករណ៍ជាអាវុធ ជារថក្រោះ កាំភ្លើងតូចធំ យន្តហោះ ហើយនិងឃើញ ប្រជាជនដែលត្រូវជម្លៀសចេញពីទីក្រុង នៅសល់មួយខ្សែ លោក ។*

អ្នកស្រី **ស សៀក** បានថ្លែងក្នុងសក្ខីកម្មថា អ្នកស្រី មិនបានឃើញក្រុមកងទ័ពអមដំណើរហ្វូងមនុស្សដែលធ្វើដំណើរចាកចេញនោះទេ នៅពេលដែលអ្នកស្រីបានមកដល់នៅក្នុងទីក្រុង។ អ្នកស្រីមិនបានដឹងថា តើនរណាជាអ្នកទទួលបន្ទុកគ្រប់គ្រងការជម្លៀស? ប៉ុន្តែអ្នកស្រីត្រូវបានគេប្រាប់ថា ហ្វូងមនុស្សត្រូវបានជម្លៀសនោះ បានទៅខុសទិសដៅដែលពួកគេចង់ទៅ។ មានប្រជាជន "ទាំងម៉ឺននាក់ដែរ" បាននាំគ្នាដើរ "របៀបថា ស្គាល់ទិសដែលត្រូវទៅ ហើយអីចឹងទៅ នាំគ្នាចេញ ទៅនេះតាមដំណើរ មើលទៅដូចធម្មតា" និងថា "តាមយល់ គេឲ្យពួកអ្នកជម្លៀសទាំងនោះ ទៅស្នាក់នៅជាបណ្តោះអាសន្នតាមភូមិកំណើតរបស់គាត់វិញសិន"។ អ្នកស្រីបានបន្តរ៉ាយរ៉ាប់ថា អ្នកស្រី បានឃើញមានទង់ពណ៌ស ត្រូវបានប្រជាជននាំគ្នាលើកឡើងនៅតាមផ្ទះ តាមអាគារមួយចំនួន ព្រមទាំងនៅពហុកីឡដ្ឋានផងដែរ ។

### *គ.៣. រចនាសម្ព័ន្ធផ្នែករដ្ឋបាល និងផ្នែកទំនាក់ទំនងរបស់កម្ពុជាប្រជាធិបតេយ្យ*

ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ អ្នកស្រី **ស សៀក** បានធ្វើការឲ្យក្រសួងឃោសនាការ ក៏ប៉ុន្តែក្រោយមក ក្រសួងនេះត្រូវបានប្រែក្លាយទៅជា ក្រសួងឃោសនា និងអប់រំ។

#### *គ.៣.ក. ក្រសួងឃោសនាការ*

អ្នកស្រី **ស សៀក** បានឲ្យដឹងថា ក្រសួងឃោសនាការ មានផ្នែកអានព័ត៌មាន (វិទ្យុ) អ្នកបច្ចេកទេស អង្គភាពបោះពុម្ព និងក្រុមការងារសិល្បៈ។ ទីស្នាក់ការរបស់ក្រសួង និងកម្មាភិបាលបម្រើការងារទាំងអស់ ត្រូវបានគេដាក់ឲ្យស្នាក់នៅក្នុងអាគារមួយ អតីតសាលា *លីសេដេកាត* ដែលមានទីតាំងជិតវត្តភ្នំ ខាងកើតស្ថានីយរថភ្លើង។ សមមិត្ត **ហ៊ូ នឹម** ជារដ្ឋមន្ត្រីនៃក្រសួងនេះ កាលពីឆ្នាំ១៩៧៥ ហើយពេលនោះ សមមិត្ត **ទីវ អុល** គឺជាជំនួយការរបស់គាត់ ប៉ុន្តែមេដឹកនាំទាំងពីររូបនេះ "បានបាត់ខ្លួន" នៅចុងឆ្នាំ១៩៧៦។[13] ក្រោយមកទៀត បុគ្គលិកមួយចំនួននៃក្រសួងនេះត្រូវបានផ្លាស់ប្តូរបុគ្គលិកថ្មីៗ ខណៈដែលអតីតក្រុមអ្នកចម្រៀង និងអ្នកអានព័ត៌មាន ត្រូវបានផ្ទេរចេញទៅធ្វើការនៅទីតាំងផ្សេងៗទៀត។ អតីតបុគ្គលិកទាំងនេះ ត្រូវបានគេប្រាប់ថា ពួកគេត្រូវបញ្ជូនចេញឲ្យទៅធ្វើស្រែនៅតាឡី ជ័យដំ និងកន្ទួត ប៉ុន្តែអ្នកស្រីមិនបានដឹងថា តើពួកគេពិតជាបានទៅទីតាំងទាំងនោះពិតប្រាកដ ឬប្តូរចេញទៅទីណាទៀតឡើយ។ អ្នកស្រីគ្រាន់តែបានបញ្ជាក់ថា អ្នកស្រីមិនដែលបានឃើញអ្នកទាំងនោះទៀតទេ។ ចំណែកឯអ្នកស្រីខ្លួនឯង ត្រូវបានគេផ្លាស់ប្តូរឲ្យទៅធ្វើការនៅក្នុងរោងពុម្ព កាលពីនៅចុងឆ្នាំ១៩៧៧ និងក្រោយមកទៀត ត្រូវបានផ្ទេរឲ្យទៅមន្ទីរ ប-២០ ដែលជាតំបន់ដីក្រហម ។

**កិច្ចប្រជុំរបស់ក្រសួង៖** បញ្ហាទាំងឡាយ រួមមានដូចជា ការសម្តែងរបស់អង្គភាពសិល្បៈ និងការថតបទចម្រៀង ត្រូវគេលើកយកទៅធ្វើកិច្ចពិភាក្សានៅក្នុងកិច្ចប្រជុំជីវភាពរបស់ក្រសួង។ ការប្រជុំទិតៀន និងស្វ័យទិតៀន គឺជាកិច្ចប្រជុំមួយ ដែលអ្នកចូលរួមបានធ្វើការរិះគន់នូវចំណុចខ្សោយ

ឬ កំហុសរបស់ខ្លួនឯង និងអ្នកចូលរួមដទៃដល់អង្គប្រជុំទាំងមូល។ អ្នកស្រីបានពន្យល់ថា កិច្ចប្រជុំទាំងនេះ ត្រូវបានធ្វើឡើងដោយគ្មានការបញ្ចេញនូវកំហឹងឡើយ ហើយជាញឹកញាប់បានលើកទឹកចិត្តឲ្យអ្នកចូលរួម ខិតខំបំពេញការងារតាមមុខនាទីរៀងៗខ្លួនឲ្យបានសម្រេច ប្រកបដោយប្រសិទ្ធភាព ។ បើយោងតាមសាក្សី បានឲ្យដឹងថា អ្នកស្រីបានចូលរួមក្នុងកិច្ចប្រជុំមួយ ដែលដឹកនាំដោយកម្មាភិបាល **ហ៊ូ នឹម** ដែលពេលនោះ មានបុគ្គលិកពីគ្រប់ផ្នែកទាំងអស់នៃក្រសួងក៏បានចូលរួមដែរ។ គោលបំណងនៃកិច្ចប្រជុំទាំងនោះ បំផុសឲ្យមានការបង្ហាញពីបទពិសោធន៍តាមផ្នែកនានាប្រយោជន៍ដើម្បីកែលម្អនូវការអនុវត្តការងារនៅក្នុងក្រសួង ។ ទោះជាយ៉ាងណាក្តី កិច្ចប្រជុំនេះត្រូវបានផ្អាកក្នុងរយៈពេលដ៏ខ្លី ព្រោះតែមានការហៅតាមទូរស័ព្ទឲ្យលោក **ហ៊ូ នឹម** ចេញទៅ ហើយតាំងពីពេលនោះមកសាក្សីមិនបានឃើញគាត់ត្រឡប់មកធ្វើការក្នុងក្រសួងវិញឡើយ។

**ស្ថានីយវិទ្យុ និងការចាក់ផ្សាយរបស់កម្ពុជាប្រជាធិបតេយ្យ៖** អ្នកស្រី **ស សៀក** បានផ្តល់សក្ខីកម្មថា អ្នកបច្ចេកទេសប្រាំមួយនាក់សល់ពីរបប **លន់ នល់** នៅតែបន្តការងារនៅស្ថានីយវិទ្យុនៅជិតវត្តភ្នំ និងបានផ្តល់ការណែនាំការងារដល់អ្នកចំណូលថ្មី។ សាក្សី **ស សៀក** បាននិយាយថា សិល្បករត្រូវបានគេជម្លៀសចេញ ប៉ុន្តែអ្នកស្រីមិនបានដឹងថា មានអ្វីកើតឡើងឡើយចំពោះក្រុមមន្ត្រីជាន់ខ្ពស់របស់ស្ថានីយវិទ្យុ។ បើទោះបីជាអ្នកស្រីមិនអាចគូសបញ្ជាក់បានពីមុខងាររបស់នាយកដ្ឋានវិទ្យុនេះក្តី អ្នកស្រីអាចត្រឹមដឹងតាមរយៈការធ្វើការនៅក្នុងចង្កោម ឬក្រសួងតែមួយថា ការផ្សាយរបស់ស្ថានីយវិទ្យុ គឺ "ជំរុញប្រជាជនឲ្យបង្កបង្កើនផល ធ្វើស្រែដើម្បីដោះស្រាយជីវភាព ហៅម៉េចថា ការម្ចាស់ការខ្លួនឯង ខ្លួនឧបត្ថម្ភខ្លួន" ព្រមទាំងបានផ្សព្វផ្សាយផងដែរអំពីស្ថានភាព ទំនាស់ និងការប៉ះទង្គិចគ្នាជាមួយប្រទេសវៀតណាម។ សាក្សីបានបន្ថែមទៀតថា បទសម្ភាសន៍ ជាខ្សែអាត់សំឡេង និងចម្លើយសារភាពរបស់ទាហានវៀតណាម ដែលត្រូវបានកងទ័ពខ្មែរក្រហមចាប់ខ្លួនបាន ពីសមរភូមិ ត្រូវបានគេចាក់ផ្សាយតាមវិទ្យុ។ អ្នកស្រី **ស សៀក** ក៏បានបញ្ជាក់នូវការឆ្លើយតបដូចគ្នានេះ នៅពេលបានឆ្លើយទៅកាន់សហចៅក្រមស៊ើបអង្កេតថា "គេធ្វើបែបនេះមែន ដើម្បីឲ្យប្រជាជនដឹងថា ទាហានវៀតណាមពិតជាត្រូវបានគេចាប់ខ្លួនមែន"។ សាក្សី **ស សៀក** ក៏បានបញ្ជាក់ផងដែរថា មានការចាក់ផ្សាយតាមវិទ្យុ ដោយបានប្រកាសថា កងទ័ពវៀតណាមបានវាយកកោះត្រល់។ ចំណែកឯការផ្សាយតាមវិទ្យុនៅពេលនោះ សាក្សី **ស សៀក** បាននិយាយថា "គឺដើម្បីអប់រំប្រជាជនឲ្យបានដឹងពីចេតនាវាតទីរបស់ប្រទេសជិតខាង ដែលរំលោភឈ្លានពាននៅព្រំដែន ដូច្នេះហើយ ឲ្យមានការឈឺចាប់លះបង់កូនចៅ ដើម្បីជួយការពារទឹកដី"។

### *គ.៣.ខ. ក្រសួងឃោសនាការ និងអប់រំ*

សាក្សី **ស សៀក** បាននិយាយឲ្យដឹងថា នៅឆ្នាំ១៩៧៧ អ្នកស្រីត្រូវបានគេបញ្ជូនទៅកាន់ការិយាល័យបោះពុម្ព។ ការិយាល័យនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងក្រសួងឃោសនាការ ដែលជាក្រោយមក បានក្លាយជាក្រសួងឃោសនាការ និងអប់រំ ក្រោមការដឹកនាំដោយអ្នកស្រី **យុន យ៉ាត** ។ ផ្នែកមួយនៃការងាររបស់សាក្សី **ស សៀក** នៅក្នុងរោងពុម្ព រួមមានដូចជា បត់ក្រដាស ធ្វើជាសៀវភៅពិនិត្យលេខទំព័រ និងរៀនចាប់ជាអក្សរពុម្ព ជាសៀវភៅទស្សនាវដ្តីរូបភាព។ នៅក្នុងបន្ទប់សវនាការនៅពេលដែលសាក្សី **ស សៀក** ត្រូវបានគេដាក់បង្ហាញផ្នែកមួយនៃច្បាប់ចម្លងចេញពីទស្សនាវដ្តីយុវ

ជន យុវនារីបដិវត្តន៍ អ្នកស្រី **ស សៀក** បានថ្លែងថា រូបភាពជាឯកសារនេះ ហាក់ដូចជាគាត់ធ្លាប់បានឃើញ ប៉ុន្តែមិនបានចាំពីការដាក់ចំណងជើងក្នុងឯកសារនេះទេ។ អ្នកស្រី មិនអាចកំណត់បាននូវការកែសម្រួលមួយកាលពីខែកញ្ញា ឆ្នាំ១៩៧៧ របស់អត្ថបទនៃទស្សនាវដ្តីទង់បដិវត្តន៍ ដោយអ្នកស្រីបានប្រាប់តុលាការថា អ្នកស្រីបានចាកចេញពីក្រសួងឃោសនាការនៅចុងឆ្នាំ១៩៧៧ ។

### *គ.៤. ប្រតិកម្មជាមួយនឹងជនជាប់ចោទ*

សាក្សី **ស សៀក** បានបង្ហាញអំពីការមានទំនាក់ទំនងផ្ទាល់ខ្លួនតិចតួចជាមួយនឹងជនជាប់ចោទ ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្នកស្រីបានរម្លឹកថា អ្នកស្រីបានឃើញ លោក **ខៀវ សំផន** ពីចម្ងាយក្នុងអំឡុងពេលនៃការធ្វើដំណើរទៅកាន់ទីក្រុងភ្នំពេញ។ អ្នកស្រី បានឃើញគាត់ម្តងទៀត នៅពេលដែលមេដឹកនាំមួយចំនួន បូករួមទាំងជនជាប់ចោទរូបនេះ បានស្នាក់នៅពីរបីថ្ងៃនៅក្នុងក្រសួងឃោសនាការ ក៏ប៉ុន្តែអ្នកស្រីមិនដែលមានឱកាសបាននិយាយជាមួយគាត់ ដោយផ្ទាល់នោះទេ ។ ទោះជាយ៉ាងណា សាក្សី **ស សៀក** បានបង្ហាញឲ្យដឹងថា អ្នកស្រីបានជួបលោក **ខៀវ សំផន** និងក្រុមគ្រួសាររបស់គាត់ តែនៅក្រោយពេលនៃការដួលរលំរបបខ្មែរក្រហមហើយ។[14] សាក្សីបាននិយាយផងដែរថា នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ អ្នកស្រីមិនដែលបានមានទំនាក់ទំនងជាមួយលោក **អៀង សារី** ឡើយ។ សហព្រះរាជអាជ្ញា **វេង ហ៊ត់** បានអាននូវសម្រង់ចេញពីសេចក្តីថ្លែងការណ៍ដែលសាក្សី **ស សៀក** បានឆ្លើយឲ្យបុគ្គលិកនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ត្រង់ចំណុចដែលអ្នកស្រីបានឆ្លើយថា "អ្នកស្រីក៏បានដឹងផងដែរពីលោក **អៀង សារី** ថា គាត់ធ្វើការនៅក្នុងក្រសួងការបរទេស" តែអ្នកស្រី **ស សៀក** បានគូសបញ្ជាក់ថា អ្នកស្រី "មិនដែលបានឃើញគាត់ផង។ ពេលនោះ គេគ្រាន់តែសួររបៀបថា ស្គាល់ ឬអត់ប៉ុណ្ណឹង។ នាងខ្ញុំឆ្លើយថា ស្គាល់" (បញ្ជាក់ពីការធ្លាប់ឮឈ្មោះលោក **អៀង សារី** តែប៉ុណ្ណោះ) ។

### *គ.៥. អត្តចរិក និង ភាពជឿជាក់ចំពោះសាក្សី*

លោកស្រី **ស សៀក** បានបង្ហាញនូវការខិតខំប្រឹងប្រែងរ៉ាយរ៉ាប់ឡើងវិញនូវព្រឹត្តិការណ៍នានាដែលបានកើតឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ បើទោះណាជាការចងចាំរបស់អ្នកស្រីចំពោះព្រឹត្តិការណ៍ទាំងនោះ ហាក់ដូចជាមានកម្រិតក៏ដោយ។ អ្នកស្រីបានប្រកាសឲ្យដឹងថា "ខ្ញុំបានសម្តែងការស្មោះត្រង់" ហើយក៏បានបន្ថែមទៀតថា "ខ្ញុំដឹង ខ្ញុំស្គាល់ត្រឹមណា ឃើញគាត់ កន្លែងត្រឹមណា ខ្ញុំបានរ៉ាយរ៉ាប់ជម្រាបលោក លោកស្រីទាំងអស់"។ ខណៈដែលអ្នកស្រី **ស សៀក** មិនអាចនឹកឃើញនូវសេចក្តីថ្លែងការណ៍មួយចំនួន ដែលគាត់ធ្លាប់បានផ្តល់ឱ្យបុគ្គលិកការិយាល័យសហចៅក្រមស៊ើបអង្កេត នៅពេលត្រូវផ្តល់សក្ខីកម្មដោយផ្ទាល់ក្នុងបន្ទប់សវនាការ អ្នកស្រីបានបញ្ជាក់អះអាងពីភាពត្រឹមត្រូវភាគច្រើននៃសេចក្តីថ្លែងការណ៍ទាំងនេះ នៅពេលដែលត្រូវបានគេអាននូវសម្រង់ខ្លីៗដើម្បីសុំឲ្យមានការបញ្ជាក់ពីអ្នកស្រី។ មានឃ្លាមួយចំនួននៃចម្លើយរបស់អ្នកស្រី ដែលបានដកស្រង់ចេញពីសេចក្តីថ្លែងការណ៍ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត ហាក់មានភាពមិនច្បាស់លាស់ ដូចជាការសំដៅទៅលើ "អ៊ំៗជាមេដឹកនាំទាំងបី" ត្រង់ចំណុចដែលថា "អ៊ំៗនិយាយថា មិនទាន់ឲ្យចូលទីក្រុងបានទេ ព្រោះប្រជាជនជម្លៀសហ្នឹងខុសទិស"។ ការលើកឡើងនេះ ហាក់ដូចជា

ចង់សំដៅទៅលើលោក **ខៀវ សំផន** លោក **ហ៊ូ នឹម** និងលោក **សុន សេន** ប៉ុន្តែអ្នកស្រីបានបញ្ជាក់ថា "អ៊ំៗ" ដែលអ្នកស្រីបានថ្លែងកន្លងទៅ គឺចង់សំដៅទៅលើកម្មាភិបាល **ហ៊ូ នឹម** កម្មាភិបាល **ទីវ អុល** និងបុគ្គលម្នាក់ទៀតដែលអ្នកស្រីមានភាពស្រពិចស្រពិល តែប្រាកដថាមិនមែនជា **សុន សេន** ទេ ។

នៅជិតចុងបញ្ចប់នៃសវនាការថ្ងៃព្រហស្បតិ៍នេះ ក្នុងពេលសួរដេញដោលលើសេចក្តីលម្អិតស្តីពីការផ្ទេរមិត្តរួមការងាររបស់អ្នកស្រីពីក្រសួង សាក្សី **ស សៀក** បានបាត់បង់នូវការផ្ចង់អារម្មណ៍របស់អ្នកស្រី ហើយបានក្លាយជាមានអារម្មណ៍ក្តុកក្តួល។ អង្គជំនុំជម្រះ បានសម្តែងនូវការយល់ដឹងពីស្ថានភាពផ្លូវអារម្មណ៍របស់សាក្សី និងបានប្រកាសផ្អាកកិច្ចដំណើរការនីតិវិធីលឿនជាងការកំណត់ ដោយយោងលើភាពសោកសង្រេងរបស់សាក្សី និងបានធ្វើការធានាឲ្យមានការយកចិត្តទុកដាក់គាំទ្រពីសំណាក់អង្គភាពគាំពារសាក្សី និងជនរងគ្រោះនៃ **អ.វ.ត.ក** ផងដែរ ។

## ផ្នែកទី៣ ៖ បញ្ហាផ្លូវច្បាប់ និងនីតិវិធី

សវនាការនាសប្តាហ៍នេះ ត្រូវបានប្រព្រឹត្តទៅជាមួយនឹងបញ្ហានីតិវិធីជាច្រើន[15] រួមទាំងភាពជម្ពះមិនប្រាកដប្រជា ទាក់ទងនឹងការប្រើប្រាស់ឯកសារយោងក្នុងការសួរដេញដោលសាក្សី និងភាពសមរម្យក្នុងការទំនាក់ទំនងគ្នារវាងសាក្សីមួយចំនួន មុនពេលពួកគាត់មកផ្តល់សក្ខីកម្ម ។

### ក. ការប្រើឯកសារក្នុងការសួរដេញដោលសាក្សី

ការយោងដោយភាគីទាំងអស់ ដោយប្រើប្រាស់នូវឯកសារនានា ក្នុងអំឡុងពេលសួរដេញដោលទៅកាន់សាក្សី មិនមែនជាបញ្ហាថ្មីនោះទេ។ នៅក្នុងខែមីនា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូង បានរារាំងភាគីមិនឲ្យប្រើប្រាស់នូវឯកសារណាមួយ ដើម្បីយកមកសួរដេញដោលលើសាក្សីប្រសិនបើសាក្សីមិនបានចងចាំ ឬមិនដែលធ្លាប់បានដឹងឮពីឯកសារនោះទេ ក៏ប៉ុន្តែអង្គជំនុជម្រះបានអនុញ្ញាតឱ្យភាគីអាចសួរជាសំណួរ ដែលមានលក្ខណៈទូទៅ ទៅលើប្រធានបទដែលខ្លួនចង់លើកឡើងបាន ។ បើទោះណាជាមានវិវាទយ៉ាងណាក្តី ក៏វិធានដែលបានសន្មតខាងដើម ភាគច្រើននៃកិច្ចដំណើរការនីតិវិធីជាបន្តបន្ទាប់ត្រូវបានអនុវត្តតាម។ អំឡុងពេលនៃការសួរដេញដោលទៅលើសាក្សី **សតឹម លួត** ដោយភាគីសហព្រះរាជអាជ្ញាកាលពីខែឧសភា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានពង្រីកនូវវិសាលភាពនៃសេចក្តីសម្រេចរបស់ខ្លួនលើបញ្ហានេះ ដោយបានអនុញ្ញាតឱ្យភាគីសហព្រះរាជអាជ្ញាធ្វើការសួរនាំសាក្សីអំពីមាតិកានៃឯកសារទាំងឡាយ ដែលត្រូវយកមកជាសម្អាងក្នុងការសួរដេញដោលរបស់ពួកគេ បើសាក្សីមានចំណេះដឹងដោយផ្ទាល់ណាមួយ បើទោះណាជាសាក្សីនោះ មិនដែលបានឃើញឯកសារនោះពីមុនក៏ដោយ មុនពេលដែលគាត់បានចូលខ្លួនមកផ្តល់សក្ខីកម្ម។[16] លើសពីនេះទៀត នៅក្នុងការឆ្លើយតបទៅនឹងសំណើរបស់ភាគីសហព្រះរាជអាជ្ញា ដែលបានស្នើសុំឲ្យមានការបំភ្លឺអំពីការប្រើប្រាស់ឯកសារនេះ [17] អង្គជំនុំជម្រះបានចេញសេចក្តីជូនដំណឹងមួយទៅកាន់ភាគីទាំងអស់នៃសំណុំរឿង គឺឯកសារ E២០១/២[18] ដែលបានផ្តល់នូវការចង្អុលបង្ហាញយ៉ាងដូច្នេះថា៖

*អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់បន្ថែមទៀតថា ការដាក់សំណើរបស់ភាគីសហព្រះរាជអាជ្ញានៅក្នុងឯកសារ E២០១ កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ ដែលក្នុងនោះ ពួកគេបានផ្តល់នូវការកត់សម្គាល់ជាបឋមមកកាន់អង្គជំនុំជម្រះ រួមទាំងភាគីដទៃទៀត ចំពោះចេតនារបស់ខ្លួនក្នុងការប្រើប្រាស់នូវឯកសារមួយចំនួន ប្រយោជន៍ដើម្បី ទី១) រម្លឹកការចងចាំរបស់សាក្សី ទី២) ផ្ទៀងផ្ទាត់នូវយថាភាពនៃឯកសារដែលនឹងត្រូវដាក់បង្ហាញ ឬដើម្បីជួយដល់អង្គជំនុំជម្រះធ្វើការវាយតម្លៃនូវទម្ងន់ ដែលនឹងត្រូវធ្វើឡើងនៅក្នុងដំណាក់កាលក្រោយមកទៀត ទី៣) ធ្វើការបញ្ជាក់ អះអាងបន្ថែមទៅលើទម្ងន់នៃឯកសារដែលមានជាសារធាតុស្រាប់ហើយនោះ ឬធ្វើសេចក្តីសរុបយថាភាពនូវសារធាតុនៃឯកសារមួយ ដោយសម្អាង ឬផ្អែកលើចំណេះដឹងដោយផ្ទាល់របស់សាក្សី ទី៤) ការប្រើប្រាស់ឯកសារដើម្បីស្ទាបស្ទង់ពីភាពគួរជឿជាក់បានរបស់សាក្សី ។*

ថ្វីបើមានការសម្រេចរបស់អង្គជំនុំជម្រះកាលពីមុនៗរួចមកហើយក្តី ដែលថាវិធីផ្សេងពីនេះបានបង្ហាញពីវិធីសាស្ត្រតូចចង្អៀតចំពោះការប្រើប្រាស់ឯកសារ នៅពេលត្រូវសួរដេញដោលទៅលើសាក្សី[19] នៅក្នុងសេចក្តីជូនដំណឹងរបស់ខ្លួនដល់ភាគីទាំងអស់ អង្គជំនុំជម្រះបានបន្ថែមថា សំណើរបស់ភាគីសហព្រះរាជអាជ្ញា គឺគ្រាន់តែជាបញ្ហាពាក់ព័ន្ធនឹងផ្លូវច្បាប់តែប៉ុណ្ណោះ[20] និងថា វាបានដើរក្នុងទិសដៅស្របគ្នានឹងការសម្រេចមុនៗរបស់អង្គជំនុំជម្រះ។[21]

ចាប់តាំងពីការចេញសេចក្តីជូនដំណឹងនោះមក ភាគីទាំងអស់បាននាំគ្នាអនុវត្តតាមនូវគោលការណ៍ណែនាំទាំងនេះ ដោយគ្មានឧប្បត្តិហេតុរាំងស្ទះបន្ថែមទៀតឡើយ ដោយសារតែ ហាក់ដូចជាមិនមានតម្រូវការចាំបាច់ក្នុងការកំណត់នូវសំណួរបន្តបន្ទាប់ណាមួយឡើយ បើសិនជាសំណួរដំបូងត្រូវបានសួរថា តើសាក្សីធ្លាប់បានស្គាល់ឯកសារឬអត់? ហើយបើចម្លើយ គឺ "មិនធ្លាប់បានស្គាល់" នោះ មានន័យថា ភាគីក៏មិនត្រូវសួរសំណួរជាបន្តរបស់ខ្លួនដោយផ្អែកលើឯកសារនោះដែរ។ ទោះជាយ៉ាងណាក្តី ក្នុងសប្តាហ៍នេះ អង្គជំនុំជម្រះបានវិលទៅរកគោលជំហរចាស់របស់ខ្លួនវិញ ដោយបានបដិសេធនូវសំណើរបស់ក្រុមមេធាវីការពារក្តីរបស់លោក **នួន ជា** ក្នុងការប្រើនូវឯកសារជាសារទូរលេខ ដែលទាក់ទងទៅនឹងដំណើរទស្សនកិច្ចមួយធ្វើឡើងដោយគណៈប្រតិភូថៃមួយក្រុម នៅក្នុងឆ្នាំ១៩៧៩[22] និងឧបសម្ព័ន្ធមួយទៀត ភ្ជាប់នឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយច្បាប់ នៅពេលដែលសាក្សី **សួង ស៊ីគឿន** បានថ្លែងថា គាត់មិនធ្លាប់បានឃើញឯកសារទាំងនេះពីមុនមកទេ។ ប្រការនេះ បានជំរុញឱ្យលោកមេធាវី **ហ្សាស្ទី ប៉ៅ** ថ្លែងទៅកាន់អង្គជំនុំជម្រះយ៉ាងដូច្នេះថា៖

*លោកប្រធាន តាមពិត ខ្ញុំនឹងគោរពតាមការសម្រេចនេះ ប៉ុន្តែលោកប្រធានដូចជាបានច្រានចោលសេចក្តីសម្រេចពីមុន ហើយវិធីដែលយើងបានប្រើក្នុងការសួរសំណួរទៅកាន់សាក្សីរហូតមកដល់ពេលនេះ គឺមានរយៈពេលពីរ ឬបីខែកន្លងមកហើយ ក្រោយចេញការសម្រេច។ តាមខ្ញុំចាំ គឺថា ប្រសិនបើសាក្សីទំនងជាអាចនឹងមានភាពពាក់ព័ន្ធ នូវប្រធានបទនៃការជជែកពិភាក្សាណាមួយនោះ ទាក់ទងនឹងកម្មវត្ថុឯកសារហ្នឹង គឺគាត់អាចអាន គាត់អាចមើល និងផ្តល់មតិយោបល់របស់ខ្លួនបាន តែបើអង្គជំនុំជម្រះប្រកាន់ជំហរ*

*ពេលនេះ វាផ្ទុយទៅនឹងគំនិតខាងដើម។ ដូច្នេះ ខ្ញុំនឹងគោរពទៅតាមសេចក្ដីសម្រេចថ្មី ប៉ុន្តែវាហាក់ដូចជាមិនយុត្តិធម៌ទេ ចំពោះការផ្លាស់ប្ដូរនីតិវិធីនៅពាក់កណ្ដាលទីនៃការសួរដេញដោលរបស់ខ្ញុំយ៉ាងដូច្នេះ។*

ជាការឆ្លើយតប លោកប្រធានតុលាការ បានទាមទារម្ដងហើយម្ដងទៀត ឲ្យមេធាវីការពារក្ដី "រកមើលឯកសារពីមុនណាមួយដែលតម្រូវឲ្យចាត់ការដូច្នេះ ហើយមានការអនុវត្តន៍ផ្ទុយពីនេះដូចម្ដេច សូមបង្ហាញយើងឥលូវនេះ ដើម្បីយើងសម្រេច!"។ លោកមេធាវី **ហ្សាស្គី ប៉ៅ** បានជូនដំណឹងត្រឡប់ទៅកាន់អង្គជំនុំជម្រះថា ក្រុមមេធាវីការពារក្ដីរបស់លោក **នួន ជា** នឹងដោះស្រាយបញ្ហានេះដោយរៀបចំនូវលិខិតជាលាយលក្ខណ៍អក្សរជូនដល់អង្គជំនុំជម្រះ នៅពេលខាងមុខឆាប់ៗ ហើយមេធាវីក៏បានចាប់ផ្ដើមសួរដេញដោលសាក្សី **សួង ស៊ីគឿន** ដោយអានសម្រង់ខ្លីៗពីឯកសារ ដែលទើបតែនឹងបានជជែកពិភាក្សានេះ។ អង្គជំនុំជម្រះបានកាត់ផ្ដាច់ចង្វាក់ចំពោះចេតនានៃការប្រើប្រាស់ឯកសារនេះរបស់លោកមេធាវី **ហ្សាស្គី ប៉ៅ** និងបានរម្លឹកដូច្នេះថា "លោកមេធាវីអាចតាំងសំណួរទៅលើខ្លឹមសារ តែមិនអនុញ្ញាតឲ្យ ខូត (ដកស្រង់) *ដោយដកស្រង់ខ្លឹមសារទាំងស្រុងចេញ ពីឯកសារនេះមកសួរដេញដោលសាក្សីទេ*" ។

នៅរសៀលថ្ងៃដដែលនោះ សហព្រះរាជអាជ្ញា បានណែនាំនូវឯកសារមួយដល់សាក្សី **ស សៀក** ប៉ុន្តែសាក្សីរូបនេះ មិនធ្លាប់បានឃើញ ឬមានទំនាក់ទំនងអ្វីជាមួយឯកសារនេះឡើយ។ វាគឺប្រតិចារឹកនៃការផ្សាយរបស់វិទ្យុបរទេស ដែលសហព្រះរាជអាជ្ញា **អាប់ឌុលហាក់** បានទទួលស្គាល់ថា "នេះមិនមែនជាឯកសារដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ" ។ មេធាវីការពារក្ដីរបស់លោក **ខៀវ សំផន** គឺលោកស្រី **អាន់តា ហ្គីសសេ** បានជំទាស់ ដោយបានទាញយកសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះកាលពីព្រឹកមកធ្វើជាសម្អាង។[23]

អង្គជំនុំជម្រះបានសម្រេចថា សហព្រះរាជអាជ្ញា "មិនចាំបាច់ប្រគល់ឯកសារនេះឲ្យសាក្សីពិនិត្យនោះទេ ហើយក៏មិនបាច់ដាក់បង្ហាញនៅលើអេក្រង់កុំព្យូទ័រដែរ។ តែអង្គជំនុំជម្រះ អនុញ្ញាតឲ្យតំណាងសហព្រះរាជអាជ្ញាប្រើប្រាស់ឯកសារនេះ ក្នុងការដេញដោលសាក្សីបាន"។ នៅពេលដែលមានការស្នើសុំឲ្យមានការគូសបញ្ជាក់នូវវិសាលភាពកម្រិតណា ដែលភាគីអាចប្រើប្រាស់នូវឯកសារបាន អង្គជំនុំជម្រះក៏បានបញ្ជាក់ថា "ដោយសារតែឯកសារនេះ ជាប្រតិចារឹកចេញពីខ្សែអាត់សំឡេងចាក់ផ្សាយតាមវិទ្យុ ដូច្នេះ ការដកស្រង់ការអាននូវខ្លឹមសារទាំងស្រុង ឬក៏ផ្នែកណាមួយដើម្បីរម្លឹកការចងចាំរបស់សាក្សី គឺអាចធ្វើទៅបាន"។ លើសពីនេះទៀត លោកចៅក្រម **ហ្សង់ម៉ាក ឡាវែន៍** បានពន្យល់ថា "ឯកសារដែលសហព្រះរាជអាជ្ញាចង់យោងយកមកប្រើនេះ គឺជាឯកសារដែលបានដាក់ទៅក្នុងសំណុំរឿងហើយ ដែលបានជជែកដេញដោលហើយ។ ឯកសារនេះ គឺថាមានលេខអ៊ី៣ (E3) រួចទៅហើយ...ឯកសារនេះបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដូច្នេះ ឯកសារនេះ អាចប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការតាំងសំណួរបាន"។ លោកចៅក្រមបានរម្លឹកភាគីផងដែរថា "ទោះជាយ៉ាងណាក៏ដោយ ជាលក្ខណៈទូទៅ គឺថាយើងធ្វើម៉េចត្រូវតែធានាឯកសារដែលត្រូវប្រើប្រាស់ គឺមានភាពពាក់ព័ន្ធនឹងសំណុំរឿងរបស់យើងបច្ចុប្បន្ននេះ" ។

ប្រការបែបនេះ បាននាំទៅរកព្រឹត្តិការណ៍ដែលជាសេចក្ដីត្រូវការចាំបាច់មួយចំពោះអង្គជំនុំជម្រះសាលាដំបូង ក្នុងការផ្ដល់នូវគោលការណ៍ណែនាំឲ្យបានច្បាស់លាស់ និងអនុវត្តគោលការណ៍

ទាំងនោះឲ្យបានជាប់លាប់ និងស្របគ្នានឹងសេចក្តីសម្រេចរបស់ខ្លួន។ យោងតាមការពន្យល់របស់លោកចៅក្រម **ឡាវែន៍** លក្ខណៈវិនិច្ឆ័យដើម្បីអនុញ្ញាតឲ្យភាគីឲ្យប្រើប្រាស់ឯកសារនូវឯកសារនានាក្នុងអំឡុងពេលសួរដេញដោលសាក្សីបាន គឺមានបីលក្ខខណ្ឌ ដូចតទៅនេះ ៖ (១) ឯកសារត្រូវតែបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ (២) សំណួរត្រូវតែមានភាពពាក់ព័ន្ធ និង (៣) សម្រង់ដែលបានអានចេញពីឯកសារ ក៏ត្រូវមានភាពពាក់ព័ន្ធគ្នាទៅវិញទៅមកផងដែរ។ តាមរយៈការចង្អុលបង្ហាញពីលោកមេធាវី **ហ្សាស្តឺ ប៉ៅ** បានឲ្យដឹងថា ឯកសារដែលគាត់ចង់ប្រើប្រាស់ គឺបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចមកហើយ ប៉ុន្តែអង្គជំនុំជម្រះនៅតែមិនទទួលបានការអនុញ្ញាតឱ្យអានជូនដល់សាក្សីស្តាប់មុនពេលធ្វើការសួរដេញដោល។[24] លើសពីនេះទៅទៀត វានឹងគួរឱ្យចាប់អារម្មណ៍ក្នុងការដឹងបានថា ចំណុចពិសេស ឬចំណុចជាក់លាក់អ្វីខ្លះទៅ ដែលអង្គជំនុំជម្រះអាចកំណត់នូវការលើកលែងចំពោះការប្រើប្រតិចារឹកនៃការចាក់ផ្សាយតាមវិទ្យុនេះ ខុសពីឯកសារផ្សេងៗទៀត ដោយតុលាការបានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាអាច "អាន ឬដកស្រង់ផ្នែកណាមួយបាន"។ ច្រើនជាងនេះទៅទៀត វាក៏ជាបញ្ហាដែលត្រូវតែស្រាយបំភ្លឺពីអង្គជំនុំជម្រះផងដែរថា តើប្រភេទឯកសារអ្វីខ្លះដែលភាគីអាចនឹងត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់បានក្នុងការសួរដេញដោលសាក្សី ហើយតើក្នុងទំហំឬដែនកម្រិតត្រឹមណា ដែលពួកគេត្រូវបានអនុញ្ញាតឲ្យយោងទៅលើឯកសារទាំងនោះបាន? ចំណុចមួយទៀតដែលលោកមេធាវី **ហ្សាស្តឺ ប៉ៅ** បានលើកឡើង គឺថា តើវាមានភាពខុសគ្នាដូចម្តេចខ្លះ ក្នុងការប្រើប្រាស់ឯកសារ ដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងឯកសារដែលមិនទាន់បានដាក់នៅឡើយទេ ក៏ប៉ុន្តែឯកសារទាំងនោះត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីឯកសាររបស់ភាគីហើយនោះ?

បញ្ហានេះនៅតែមិនទាន់ដោះស្រាយរហូតដល់ចុងសប្តាហ៍នៃសវនាការ ដោយអង្គជំនុំជម្រះបានណែនាំដល់ភាគីថា នឹងលើកយកបញ្ហានេះទៅពិភាក្សានៅក្នុងអំឡុងពេលនៃសវនាការស្តីពីការរៀបចំគ្រប់គ្រងសវនាការរបស់តុលាការនៅថ្ងៃបន្ទាប់។ ទាំងភាគីសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តីលោក **នួន ជា** បានយល់ព្រមទៅនឹងហេតុផលនៃសេចក្តីត្រូវការមួយក្នុងការទទួលយកនូវវិធីសាស្ត្រទូលំទូលាយ ដើម្បីដោះស្រាយលើបញ្ហានេះ ដូច្នេះ វានឹងមានប្រយោជន៍ដល់អង្គជំនុំជម្រះក្នុងការពិនិត្យឡើងវិញនូវសម្អាងហេតុនៅពីក្រោយសេចក្តីសម្រេចនេះ និងធ្វើការកំណត់ថា តើការសម្រេចកន្លងទៅនៅតែអាចឆ្លើយតបទៅនឹងអ្វីដែលជាតម្រូវការផ្លូវច្បាប់ និងការអនុវត្តន៍ជាក់ស្តែងចំពោះដំណើរការកាត់សេចក្តីនៃសំណុំរឿងនេះ? មានការសង្ឃឹមទុកថា បញ្ហាដែលបានកើតឡើងជាថ្មីម្តងទៀតនេះ ទីបំផុតនឹងត្រូវបានដោះស្រាយយ៉ាងមានប្រសិទ្ធភាព នៅត្រឹមអំឡុងពេលនៃកិច្ចប្រជុំរៀបចំគ្រប់គ្រងសវនាការក្នុងសប្តាហ៍នេះ ។

### ខ. ទំនាក់ទំនងរវាងសាក្សីជាមួយនឹងសាក្សីផ្សេងទៀតមុនពេលផ្តល់សក្ខីកម្ម[25]

ក្នុងពេលកំពុងធ្វើការសួរដេញដោលសាក្សី **សួង ស៊ីគឿន** ដោយលោកមេធាវីការពារក្តី **ហ្សាស្តឺ ប៉ៅ** និងលោក **កាណាវាស** សាក្សីបានសារភាពថា មុនពេលគាត់បង្ហាញខ្លួនមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ គាត់បានធ្វើការប្រាស្រ័យទាក់ទងគ្នាជាមួយសាក្សីម្នាក់ទៀត ឈ្មោះ **ភី ភួន** មុនពេលសាក្សីរូបនេះ និងរូបគាត់បានធ្វើដំណើរចេញពីស្រុកកំណើត ដើម្បីមកផ្តល់សក្ខីកម្មនៅ

អ.វ.ត.ក។ សាក្សី ក៏បានចង្អុលបង្ហាញផងដែរថា មុនពេលមកផ្តល់សក្ខីកម្ម គាត់ផ្ទាល់ និងលោក **ភី ភួន** បានជួបគ្នាជាលើកទីពីរនៅក្នុងសណ្ឋាគារមួយ នៅរាជធានីភ្នំពេញខណៈពេលដែលលោក **ភី ភួន** "គាត់ស្រស់ស្រូបអាហារពេលព្រឹកជាមួយនឹងតំណាងរបស់អង្គភាពគាំពារសាក្សីម្នាក់"។ ខណៈពេលដែលសាក្សី **សួង ស៊ីគឿន** បានធានាចំពោះអង្គជំនុំជម្រះថា ពួកគាត់ "មិនបាននិយាយអីពាក់ព័ន្ធនឹងតុលាការទេ" ប៉ុន្តែតពីនេះទៀត គាត់បាននិយាយថា "ហេតុអ្វីដែលខ្ញុំបានសុំជួបគាត់ គឺខ្ញុំចង់ដឹងថា គេសួរអីច្បាស់លាស់អីចឹងទេ ដើម្បីខ្ញុំស្រួលឆ្លើយនឹងសំណួររបស់តុលាការ..."។ សាក្សីបានបន្ថែមទៀតថា គាត់ក៏ចង់ដឹងផងដែរថា តើមានព័ត៌មានអ្វីខ្លះដែលតុលាការមិនចង់ស្តាប់ពីខ្ញុំ ហើយបើខ្ញុំបានដឹងជាមុនដូច្នេះ ខ្ញុំនឹងមិនប្រាប់រឿងរ៉ាវទាំងនោះដល់តុលាការដែរ"។ សាក្សី **សួង ស៊ីគឿន** ក៏បានទទួលស្គាល់ដែរថា គាត់បានតាមដាននូវការផ្តល់សក្ខីកម្មរបស់សាក្សី **ភី ភួន** និងថែមទាំងបានថ្លែងយោបល់ថា "តាមដែលខ្ញុំចាំក្នុងសក្ខីកម្មរបស់គាត់ហ្នឹង ក៏គាត់និយាយត្រង់ច្រើនដែរបាទ"។ នៅពេលដែលត្រូវបានចោទសួរថា តើគាត់បានដឹងអ្វីខ្លះពីសក្ខីកម្មរបស់សាក្សីផ្សេងម្នាក់ទៀត ឈ្មោះ **សូ ហុង** ជាអតីតកម្មាភិបាលម្នាក់ដែលធ្លាប់បានបម្រើការងារនៅក្រសួងការបរទេស លោក **សួង ស៊ីគឿន** បានថ្លែងថា លោកមិនដែលមានទំនាក់ទំនងជាមួយលោក **សូ ហុង** ទេ[26] ប៉ុន្តែក្រោយមក គាត់ក៏បានដឹងថាមានឈ្មោះបុគ្គលម្នាក់នេះ ផ្តល់សក្ខីកម្មតាមរយៈការផ្សាយផ្ទាល់តាមទូរទស្សន៍។

ទាំងភាគី ក៏ដូចជាអង្គជំនុំជម្រះ សុទ្ធតែមិនបានផ្តល់មតិយោបល់អ្វីទាំងអស់លើរឿងហេតុដែលបានបញ្ចេញឲ្យដឹងដូចបានរៀបរាប់ខាងលើ ទោះបីជារឿងរ៉ាវដែលបានកើតឡើងទាំងនេះមានការជាប់ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍កាលពីខែកក្កដាកន្លងទៅថ្មីៗក៏ដោយ នៅពេលដែលសាក្សី **ភី ភួន** បានទទួលស្គាល់ថា លោកផ្ទាល់បានចូលរួមតាមដានដំណើរការនីតិវិធីតុលាការស្តីពី "សវនាការបើកការចោទប្រកាន់" របស់ភាគីសហព្រះរាជអាជ្ញា នៅក្នុងខែវិច្ឆិកាពីសាលសាធារណជន។[27] គួរឲ្យកត់សម្គាល់ថា បញ្ហានេះ ត្រូវបានលើកយកមកពិភាក្សាតាំងពីនៅក្នុងដំណើរការនីតិវិធីសវនាការបឋម ក្នុងខែធ្នូ ឆ្នាំ២០១១ មកម្ល៉េះ ដែលខណៈពេលនោះ អង្គជំនុំជម្រះបានទទួលស្គាល់ចំពោះបញ្ហានេះព្រមទាំងផលលំបាកចំពោះការដាក់កម្រិតនូវការធ្វើឲ្យគេដឹង (ដឹងព័ត៌មានពីតុលាការ ពីព្រោះជាតុលាការសាធារណៈ ដែលជាហេតុនាំឲ្យសាក្សីអាចយល់ការមួយចំនួនបានតាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ រួមមានទូរទស្សន៍ ឬកាសែតជាដើម) របស់សាក្សីដែលត្រូវចូលខ្លួនមកផ្តល់សក្ខីកម្ម។ ចៅក្រម **ឡាវែន៍** បានរម្លឹកភាគីថា នេះមិនមែនជាបទបញ្ជាចាំបាច់នោះទេ ប៉ុន្តែជាកាតព្វកិច្ចទូទៅដែលតម្រូវឲ្យអង្គភាពគាំពារសាក្សី និងជនរងគ្រោះត្រូវតែអនុវត្តមុខងារ តាមបទដ្ឋានអង្គភាពរបស់ខ្លួន។[28] ទោះជាយ៉ាងណា អ្វីដែលគួរឲ្យចង់ដឹងនៅក្នុងករណីនេះ គឺថាសាក្សីបានជួបគ្នានៅក្នុងពេលមានវត្តមានរបស់អ្នកតំណាងអង្គភាពគាំពារសាក្សី និងជនរងគ្រោះនៅទីនោះដែរ ដែលប្រការនេះ វាគួរតែជាការទទួលខុសត្រូវរបស់អ្នកតំណាងរូបនោះ ក្នុងការទប់ស្កាត់នូវឧប្បត្តិហេតុទាំងនេះមិនឲ្យកើតមានឡើង។ នៅខណៈពេលដែលវាមានផលលំបាក ក្នុងការទប់ស្កាត់សាក្សីមិនឲ្យពួកគាត់ទទួលបាននូវព័ត៌មាននានាទាក់ទងនឹងសំណុំរឿង០០២ តាមប្រភពផ្សេងៗបាន ការទប់ស្កាត់សាក្សីមិនឲ្យពួកគាត់ធ្វើការពិភាក្សាគ្នា អំពីបញ្ហាទាក់ទងទៅនឹងកិច្ចដំណើរការនីតិវិធី នៅមុនពេលពួកគាត់ចូលខ្លួនមកផ្តល់សក្ខីកម្ម គឺជាហេតុផលសមរម្យ ដែលគួរតែអាចធ្វើបានប្រកបដោយជោគជ័យ។[29]

## គ. ការដកចេញនូវសក្ខីកម្មរបស់សាក្សី

នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២ ក្រុមមេធាវីការពារក្តីលោក **នួន ជា** បានទាញការចាប់អារម្មណ៍ពីតុលាការឲ្យពិចារណាលើអត្ថបទព័ត៌មានរបស់កាសែត *ខេមបូឌា ឌេលី* ត្រង់ចំណុចដែលលោក **ភី ភួន** (ហៅ **រចាម ទុន**) បានដកសម្តីរបស់ខ្លួនដែលបានថ្លែងក្នុងសក្ខីកម្មពីមុនរបស់គាត់ថា លោក **ហោ ណាំហុង** ជាប្រធាននៅបឹងត្របែកនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។[30] លោកមេធាវី **ហ្សាស្គី ប៉ៅ** បានសួរទៅកាន់សាក្សី **សួង ស៊ីគឿន** អំពីបញ្ហានេះនៅក្នុងបន្ទប់តុលាការថា តើសាក្សី បានដឹងឮទេថា លោក **ភី ភួន** បានដកសម្តី ឬការថ្លែងពីមុនរបស់គាត់? ភាគីសហព្រះរាជអាជ្ញាបានជំទាស់ ដោយលើកហេតុផលថា វាមិនមែនជាការសមរម្យក្នុងការសួរឲ្យសាក្សីបច្ចុប្បន្ននេះធ្វើការអត្ថាធិប្បាយទៅលើអ្វីដែលសាក្សីផ្សេងបានថ្លែង។ លោក **ហ្សាស្គី ប៉ៅ** បានតវ៉ាថា ការលើកឡើង គឺមានភាពពាក់ព័ន្ធទៅនឹងចម្ងល់ថា តើសាក្សីរូបនេះ គឺលោក **សួង ស៊ីគឿន** ត្រូវបានរងឥទ្ធិពលពីប្រភពខាងក្រៅដែរឬទេ ចំពោះការមកផ្តល់សក្ខីកម្មរបស់គាត់? អង្គជំនុំជម្រះបានយល់ឃើញថា សំណួររបស់លោកមេធាវី **ប៉ៅ** គឺមិនមានភាពទាក់ទងនីតិវិធីសវនាការបច្ចុប្បន្ន និងបានគាំទ្រនូវការជំទាស់របស់សហព្រះរាជអាជ្ញា។

ការដកចេញនូវចម្លើយរបស់លោក **ភី ភួន** ប្រសិនបើពិតវិញ វានឹងនាំឲ្យលេចចេញនូវបញ្ហាមួយចំនួន ទំនងអាចជាការជ្រៀតជ្រែកផ្នែកនយោបាយ ដែលក្រុមមេធាវីការពារក្តីលោក **នួន ជា** តែងតែអះអាងជាញឹកញាប់ ហើយនិងវិសាលភាពនៃការគាំពារ ព្រមទាំងការការពារ ដែល អ.វ.ត.ក ផ្តល់ឲ្យសាក្សី។ លើសពីនេះទៀត ក្រៅពីបន្ទុចបង្អាក់នូវភាពជឿជាក់ទៅលើលោក **ភី ភួន** ក៏ដូចជាបង្អកសក្ខីកម្មរបស់បុគ្គលរូបនេះ ឲ្យនៅជាសំណួរដែលត្រូវជជែកពិភាក្សានៅពេលសមរម្យណាមួយនោះ ការចោទប្រកាន់ចំពោះការដកចេញនូវសេចក្តីថ្លែងការណ៍របស់គាត់ អាចជាលទ្ធផលយ៉ាងមានសក្តានុពល ចំពោះចំណាត់ការតាមផ្លូវច្បាប់ប្រឆាំងនឹងរូបគាត់បាន។ នៅក្រោមវិធានផ្ទៃក្នុង ៣៦ (២) (កំណែថ្មី គឺវិធានផ្ទៃក្នុង ៣៥(២) ស្តីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ) បានចែងថា នៅពេលដែលអង្គជំនុំជម្រះមានហេតុផលជឿថា បើមានសាក្សីណាម្នាក់បានដឹង និងមានចេតនាផ្តល់នូវសក្ខីកម្មមិនត្រឹមត្រូវដល់តុលាការនោះ អង្គជំនុំជម្រះអាចនឹង (ក) ចាត់ការជាមួយបញ្ហានេះជាបន្ទាន់ (ខ) នឹងដឹកនាំនូវការស៊ើបសួរបន្ថែម ដើម្បីឲ្យដឹងប្រាកដថា តើមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ចាត់ការតាមនីតិវិធី ឬ (គ) បញ្ជូនបញ្ហានេះ ទៅឲ្យអាជ្ញាធរមានសមត្ថកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ឬអង្គការសហប្រជាជាតិ ។

## ឃ. តួនាទីរបស់សាក្សីក្នុងការឆ្លើយតបនឹងសំណួរ

សាក្សីមានកាតព្វកិច្ចនៅក្នុងការឆ្លើយនូវរាល់សំណួរ ដែលសួរដោយភាគីទាំងអស់នៃសំណុំរឿង លុះត្រាតែសេចក្តីថ្លែងការណ៍របស់សាក្សីណាម្នាក់នោះ មិនមានទំនោរឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯង[31] ហើយនិងថ្លែងតែការពិតនៅក្នុងការផ្តល់សក្ខីកម្មរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះ។[32] ទោះជាយ៉ាងនេះក្តី កាលពីថ្ងៃពុធ លោក **សួង ស៊ីគឿន** បានបដិសេធមិនឆ្លើយសំណួរមួយចំនួនដែលលោកបានចាត់ទុកថា ជាសំណួរច្រំដែល ហើយគាត់ក៏បានសុំយោបល់ពីប្រធានតុលាការអំពីថាតើជាការគួរសម្រាប់គាត់ឆ្លើយតបដែរឬទេ ចំពោះសំណួរដែលទាក់ទងនឹងមន្ត្រីថ្នាក់ខ្ពស់នៃរាជរដ្ឋា

ភិបាលនាពេលបច្ចុប្បន្ននេះ? គួរឱ្យភ្ញាក់ផ្អើលលោកប្រធានតុលាការ បានធ្វើការណែនាំដល់សាក្សី **សួង ស៊ីគឿន** ដូចខាងក្រោម:

> *បាទ អរគុណសាក្សី។ ឥឡូវអីចេះ យើងសូមរម្លឹកសាក្សីម្តងទៀត ចាប់ពីពេលនេះទៅ លោកអាចស្តាប់នូវសំណួរដែលបានសួរ ព្រោះលោកអាចមានបញ្ហាវាងវៃ លោកជាបញ្ញាជន ។ បើសិនជាសំណួរច្រំដែល គឺលោកមិនអាចឆ្លើយតបក៏បានដែរ ឬក៏សុំមកយើង ដើម្បីយើងសម្រេចថា មិនឲ្យឆ្លើយតបទៅនឹងសំណួរច្រំដែលទេ។ ព្រោះ យើងស្តាប់ច្រើននៅក្នុងសវនាការប៉ុន្មានថ្ងៃនេះ យើងកត់សម្គាល់ឃើញសំណួរច្រំដែលច្រើន ជាពិសេស ប្រភេទសំណួរដែលភាគីសួរផ្ចាញ់សាក្សី។ ទីពីរ ចំពោះប្រភេទសំណួរផ្សេងទៀត លោកបង្អង់សិន ប្រសិនបើសំណួរ មានទំនោរឲ្យលោកឆ្លើយ "បាទ" ឬក៏ "ទេ" (សំណួរដឹកមុខ)។ សំណួរប្រភេទនេះ គឺអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យប្រើប្រាស់នៅក្នុងអង្គសវនាការរបស់ អ.វ.ត.ក ទេ ។*

ដោយការផ្តល់បុព្វសិទ្ធិដល់សាក្សីម្នាក់ ក្នុងការបដិសេធមិនឆ្លើយនូវសំណួរទាំងឡាយ ជាឯកតោភាគី នៅពេលសាក្សីរូបនោះដឹងថា សំណួរដែលបានសួរជាច្រំដែល ឬជាសំណួរនាំមុខ គឺជាការបង្ហាញឲ្យឃើញថា អង្គជំនុំជម្រះបានធ្វើឲ្យសាបរលាបនូវអំណាចរបស់ខ្លួនក្នុងការកំណត់ថា តើសំណួរណាដែលចាត់ទុកថា ជាសំណួរមិនសមរម្យក្នុងពេលភាគីកំពុងសួរដេញដោលសាក្សី ហើយដែលអំណាចនេះ គួរតែត្រូវបានកាន់កាប់ជាអំណាចផ្តាច់មុខរបស់អង្គជំនុំជម្រះខ្លួនឯង។[33] ការធ្វើដូច្នេះ អាចជាការកំណត់នូវគំរូមិនសមរម្យមួយសម្រាប់សាក្សីផ្សេងៗទៀត និងថែមទាំងបើកលទ្ធភាពឲ្យសាក្សីនានា ដើម្បីធ្វើការបដិសេធមិនឆ្លើយតបនឹងសំណួរ ដោយគ្រាន់តែមូលហេតុដែលពួកគេយល់ឃើញថា ជាសំណួរមិនគួរឲ្យចង់ឆ្លើយ ឬជាសំណួរដែលពួកគេមិនពេញចិត្តនឹងឆ្លើយ។

## ង. សិទ្ធិរបស់ជនជាប់ចោទក្នុងការមានវត្តមាននៅក្នុងការជំនុំជម្រះក្តីរបស់គាត់

សិទ្ធិរបស់ជនជាប់ចោទក្នុងការមានវត្តមាន នៅក្នុងដំណើរការកាត់ទោសនេះ ត្រូវបានដាក់បញ្ចូលក្នុងមាត្រា ៣៥ ថ្មី (ឃ) នៃច្បាប់របស់ អ.វ.ត.ក និងនៅក្នុងវិធានផ្ទៃក្នុង ៨១(១) ។ សិទ្ធិនេះត្រូវបានគូសបញ្ជាក់ជាថ្មីម្តងទៀតនៅសប្តាហ៍នេះ ដោយសារស្ថានភាពសុខភាពទ្រុឌទ្រោមរបស់ជនជាប់ចោទ **អៀង សារី** និងកិច្ចខិតខំប្រឹងប្រែងរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការផ្តល់នូវឱកាសសម្រាប់ជនជាប់ចោទ ដើម្បីចូលរួមក្នុងដំណើរការនីតិវិធីសវនាការ ។[34]

ដោយពិចារណាទៅលើលិខិតសុំលះបង់សិទ្ធិបច្ចុប្បន្ននេះ ដែលបានស្នើសុំមិនបង្ហាញខ្លួនក្នុងបន្ទប់សវនាការ ដោយសារតែសារៈសំខាន់នៃការចូលខ្លួនមកផ្តល់សក្ខីកម្មរបស់សាក្សីមួយចំនួន ព្រមទាំងរបាយការណ៍ដែលបានរកឃើញថា លោក **អៀង សារី** មិនមានអារម្មណ៍ស្រួលបួលគ្រប់គ្រាន់ដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការបាន អង្គជំនុំជម្រះ បានកោះហៅក្រុមគ្រូពេទ្យប្រចាំតុលាការ គឺលោកវេជ្ជបណ្ឌិត **គឹម សមសាន្ត** ដើម្បីផ្តល់នូវការរកឃើញរបស់គាត់ចំពោះស្ថានភាពសុខភាពរបស់ជនជាប់ចោទ។ យោងតាមលោកវេជ្ជបណ្ឌិតបានឲ្យដឹងថា លោក **អៀង សារី** បានត្អូញថា "អារម្មណ៍របស់គាត់ពេលនេះ គឺអស់កំលាំងខ្លាំង វិលមុខ ហើយអារម្មណ៍ច្របូកច្របល់

...គាត់ភ្លេចភ្លាំងច្រើន។ លោកវេជ្ជបណ្ឌិតបានបង្ហាញថា "គាត់មិនមានលទ្ធភាពវាយតម្លៃនូវអាការៈចងចាំ ឬបញ្ហាស្មារតីរបស់លោក **អៀង សារី** ឲ្យបានត្រឹមត្រូវនោះទេ ដូច្នេះ ជាទូទៅ គាត់អាចធ្វើការគាត់សម្គាល់បានផ្អែកលើតែអ្វីដែលជនជាប់ចោទបានប្រាប់គាត់តែប៉ុណ្ណោះ។ ដោយគោរពនូវសិទ្ធិរបស់ជនជាប់ចោទ **អៀង សារី** ដែលបានលះបង់សិទ្ធិមិនមានវត្តមាននៅក្នុងកិច្ចដំណើរការកាត់ទោសលើរឿងក្ដីរបស់គាត់ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចចិត្តពន្យារពេលសវនាការវគ្គពេលព្រឹក ដើម្បីវាយតម្លៃការវិវឌ្ឍន៍លើស្ថានភាពសុខភាពរបស់លោក **អៀង សារី**។ សវនាការវគ្គរសៀលនាថ្ងៃដដែលនេះ អង្គជំនុំជម្រះ បានប្រកាសផ្អាកសវនាការសម្រាប់ពេលវេលាដែលនៅសល់នៃថ្ងៃនេះ ដោយសារលោក **អៀង សារី** នៅតែមានអារម្មណ៍ទន់ខ្សោយពេក និងមិនងអាចចូលរួមកិច្ចដំណើរការនីតិវិធីសវនាការបាន។

## ផ្នែកទី៤៖ ការគ្រប់គ្រងសវនាការ

មានការប្រឈមមួយចំនួន ចំពោះបញ្ហានៃការគ្រប់គ្រងកិច្ចដំណើរការនីតិវិធីនៅសប្ដាហ៍នេះ ដោយសារតែអង្គជំនុំជម្រះសាលាដំបូង ចាំបាច់ត្រូវដោះស្រាយនូវកង្វល់ផ្នែកសុខភាពរបស់ជនជាប់ចោទ **អៀង សារី** និងបញ្ហាសុខភាពរបស់សាក្សី **សួង ស៊ីគឿន** ក៏ដូចជាត្រូវប្រឈមផងដែរនូវបញ្ហានីតិវិធីមួយចំនួន ដែលបានលេចឡើងក្នុងអំឡុងពេលដំណើរការនីតិវិធីសវនាការ។

### ក. វត្តមាន

ដោយសារតែសុខភាពទន់ខ្សោយរបស់លោក **អៀង សារី** បានជាអង្គជំនុំជម្រះត្រូវបង្ខំចិត្តផ្អាកនូវកិច្ចដំណើរការនីតិវិធីពេញមួយថ្ងៃចន្ទ។ លោក **អៀង សារី** បានចូលរួមតាមដានសវនាការពីបន្ទប់សោតទស្សន៍នៅពេលវេលាដែលនៅសេសសល់នៃសប្ដាហ៍នេះ ដោយសារតែស្ថានភាពរបស់គាត់។ ចំណែកឯជនជាប់ចោទ **នួន ជា** វិញ មានវត្តមាននៅក្នុងបន្ទប់សវនាការតែក្នុងអំឡុងសវនាការវគ្គពេលព្រឹក ក៏ប៉ុន្តែបានស្នើសុំចូលរួមពីចម្ងាយពីបន្ទប់សោតទស្សន៍វិញ នៅវគ្គសវនាការ វគ្គរសៀល។ ដូចសព្វមួយដង មានតែជនជាប់ចោទ **ខៀវ សំផន** តែប៉ុណ្ណោះ ដែលបានចូលរួមតាមដានពីបន្ទប់សវនាការដោយផ្ទាល់ពេញមួយសប្ដាហ៍នេះ។

**វត្តមានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី៖** ទីកន្លែងអង្គុយចំនួនច្រើនជាង ១០កៅអី ក្នុងសាលសវនាការ ត្រូវបានបម្រុងដើម្បីទុកសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី។ ពួកគាត់បានអង្គុយពេញកន្លែងបម្រុងទុកទាំងអស់នោះ ក្នុងអំឡុងកិច្ចដំណើរការនីតិវិធី ។

**ការចូលរួមពីសាធារណជន៖** នៅតែមានចំនួននៃអ្នកចូលរួមខ្ពស់នៅសាលសាធារណជនសម្រាប់សប្ដាហ៍នេះ។ កាលពីថ្ងៃចន្ទ មានអ្នកភូមិប្រហែលជា ២៥០ នាក់ មកពីខេត្តកណ្ដាល ខេត្តតាកែវ និងខេត្តកំពង់ស្ពឺ បានចូលរួមតាមដាននៅក្នុងពេលព្រឹក។ មានអ្នកភូមិប្រមាណជា ២០០ នាក់ មកពីខេត្តតាកែវ បានចូលខ្លួនមកជំនួសនៅក្នុងវគ្គរសៀល។ នៅថ្ងៃបន្ទាប់ មានការកើនឡើងនូវចំនួនអ្នកចូលរួម ដោយរួមបញ្ចូលទាំងចំនួនភ្ញៀវបរទេសប្រមានជា ១០០ នាក់ បូកនឹងចំនួនអ្នកភូមិប្រមាណជា ៣០០ នាក់ ផ្សេងទៀត មកពីស្រុកបាកាន ខេត្តពោធិសាត់ បានចូលរួមក្នុងវគ្គពេលព្រឹក។ នៅពេលរសៀលវិញ មានអ្នកភូមិប្រមាណជា ២០០ នាក់ មកពីស្រុកត្រាំកក់ ខេត្តតាកែវ

បានចូលរួមតាមដានក្នុងកិច្ចដំណើរការនីតិវិធី ។ កាលពីថ្ងៃពុធ មានអ្នកភូមិប្រមាណជា ២៥០ នាក់ មកពីខេត្តកំពត និងខេត្តកំពង់ឆ្នាំង បានចូលរួមសវនាការវគ្គពេលព្រឹក ចំណែកឯពេលរសៀលវិញ មានអ្នកភូមិមកពីខេត្តដូចគ្នានេះ ប្រមាណជា ៣០០ នាក់ បានចូលរួមក្នុងសវនាការវគ្គរសៀល។ ក៏មានភ្ញៀវបរទេសប្រមាណជា ៥០ នាក់ ក៏មានវត្តមានផងដែរ នៅក្នុងវគ្គរសៀល។ នៅថ្ងៃចុងក្រោយនៃដំណើរការនីតិវិធីសវនាការសម្រាប់សប្តាហ៍នេះ ឃើញមានអ្នកភូមិប្រមាណជា ៤០០ នាក់ មកពីខេត្តក្រចេះ ខេត្តកណ្តាល និងខេត្តកំពង់ឆ្នាំង បូករួមទាំងក្រុមនិស្សិតចំនួន ៥៣ នាក់ មកពីអង្គការ *កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន* (YRDP) ក៏បានចូលរួមតាមដានសវនាការនេះផងដែរ។ នៅពេលរសៀល មានអ្នកភូមិច្រើនជាង ២០០ នាក់ មកពីខេត្តកណ្តាល មានវត្តមាននៅក្នុងសាលសាធារណជន ។

## ខ. បញ្ហានៃការបកប្រែ

បើទោះជាបញ្ហានៃការបកប្រែនៅតែកើតមានឡើង ក៏វាមិនលេចចេញនូវការកត់សម្គាល់ជាដុំកំភួនដែរសម្រាប់សវនាការនាសប្តាហ៍នេះ។ យើងបានកត់សម្គាល់ថា មានឱកាសមួយចំនួន ដែលកាលបរិច្ឆេទរ៉ាយរ៉ាប់ពីព្រឹត្តិការណ៍ជាក់លាក់ផ្សេងៗ មិនត្រូវបានបកប្រែត្រឹមត្រូវឡើយ ហើយមានពេលមួយនោះ មិនមានការបកប្រែជាភាសាអង់គ្លេសទេ ត្រង់ចំណុចដែលមេធាវី **អាន់តា ហ្គីសសេ** បានក្រោកឈរឡើង ដើម្បីបង្ហាញនូវការសង្កេតរបស់ខ្លួន នៅពេលដែលសាក្សី **ស សៀក** កំពុងត្រូវបានសួរដេញដោលដោយភាគីសហព្រះរាជអាជ្ញា។

## គ. ការគ្រប់គ្រងពេលវេលា

អង្គជំនុំជម្រះសាលាដំបូង បានកែប្រែកាលវិភាគសវនាការនៅសប្តាហ៍នេះ ដោយសារលទ្ធផលនៃបញ្ហាសុខភាពរបស់លោក **អៀង សារី** និងសេចក្តីត្រូវការផ្សេងៗរបស់សាក្សីនានា។ ព្រោះតែស្ថានភាពសុខភាពរបស់លោក **អៀង សារី** ស្ថិតក្នុងការព្រួយបារម្ភយ៉ាងខ្លាំង រហូតដល់មិនអាចចូលរួមតាមដានកិច្ចដំណើរការនីតិវិធីបាន ឧបសគ្គនេះ តម្រូវឲ្យអង្គជំនុំជម្រះបានប្រកាសផ្អាកសវនាការកាលពីថ្ងៃចន្ទ។ លើសពីនេះទៅទៀត ដោយសារតែសំបុត្រយន្តហោះរបស់លោក **អ៊ុង ចុងហឿង** សម្រាប់ធ្វើដំណើរវិលត្រឡប់ទៅកាន់ប្រទេសបែលហ្ស៊ិក មិនអាចពន្យារពេលបាន ទើបអង្គជំនុំជម្រះបានផ្តល់អាទិភាពឲ្យដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ អាចផ្តល់សក្ខីកម្មជូនតុលាការបាននៅថ្ងៃអង្គារ។ បញ្ហាមួយទៀត ដើម្បីផ្តល់ឱកាសឲ្យសាក្សី **សួង ស៊ីគឿន** បានសម្រាកព្យាបាលសុខភាពរបស់គាត់ ដែលបានកើតឡើងក្នុងអំឡុងពេលផ្តល់សក្ខីកម្ម អង្គជំនុំជម្រះក៏បានអនុញ្ញាតឲ្យសាក្សីរូបនេះធ្វើការផ្តល់សក្ខីកម្មរបស់គាត់បាន តែនៅវគ្គខ្លះនៃសវនាការប្រចាំថ្ងៃក្នុងសប្តាហ៍នេះ។ លទ្ធផលនៃការផ្តល់សក្ខីកម្មចោះៗរបស់សាក្សី **សួង ស៊ីគឿន** ដោយសារតែបញ្ហាសុខភាពដែរនោះ បានផ្តល់ឱកាសឲ្យសាក្សីបម្រុង គឺអ្នកស្រី **ស សៀក** ចូលខ្លួនមកបំពេញចន្លោះនៅវគ្គមួយចំនួននៃកិច្ចដំណើរការនីតិវិធីសវនាការ បន្ទាប់ពីវគ្គសម្រាកទទួលទានអាហារថ្ងៃត្រង់កាលពីថ្ងៃពុធ ។

## ឃ. តារាងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្តើម | សម្រាកពេលព្រឹក | អាហារថ្ងៃត្រង់ | សម្រាកពេលរសៀល | ផ្អាកសវនាការ | រយៈពេលសវនាការសរុប |
|---|---|---|---|---|---|---|
| ថ្ងៃចន្ទ ១៣/០៨/១២ | ៩:២៤ | ០៩:៥៥ | - | ១៣:៤៤ | ១៣:៥០ | ៣៧នាទី |
| ថ្ងៃអង្គារ ១៤/០៨/១២ | ៩:០០ | ១០:៣១-១០:៥១ | ១២:០៧-១៣:៣១ | ១៤:៤០-១៥:០១ | ១៦:០៤ | ៤ម៉ និង ៥៩នាទី |
| ថ្ងៃពុធ ១៥/០៨/១២ | ៩:០១ | ១០:៣៦-១០:៥៦ | ១២:០៥-១៣:៣១ | ១៤:៤២-១៥:០២ | ១៦:០៤ | ៤ម៉ និង ៥៧នាទី |
| ថ្ងៃព្រហស្បតិ៍ ១៦/០៨/១២ | ៩:០៧ | ១០:៣២-១០:៥៥ | ១២:១៤-១៣:៣២ | ១៤:៤២-១៥:០១ | ១៥:៥៥ | ៤ម៉ និង ៤៨នាទី |
| *រយៈពេលសវនាការជាមធ្យម* | | | | *៣ ម៉ោង និង៥០នាទី* | | |
| *រយៈពេលសវនាការសរុបក្នុងសប្តាហ៍នេះ* | | | | *១៥ ម៉ោង និង២១នាទី* | | |
| *ចំនួនម៉ោង ថ្ងៃ និង សប្តាហ៍នៃសវនាការ* | | | | *៤២០ម៉ោង និង២៤នាទី* | | |
| *រយៈពេលសវនាការចំនួន ៩៦ ថ្ងៃ អំឡុងពេល ២៨សប្តាហ៍* | | | | | | |

**Unless specified otherwise,**

- the documents cited in this report pertain to *The Case of NuonChea, IengSary, IengThirith and KhieuSamphan* before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings;
- the figures in the *Public Attendance* section of the report are only approximations; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of KaingGuekEav alias "Duch"*(Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of NuonChea, IengSary, IengThirith and KhieuSamphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

* AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

This issue of KRT TRIAL MONITOR was authored by Mary Kristerie A. Baleva, Princess B. Principe, Sovanna Sek, Kimsan Soy, and Penelope Van Tuyl, as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT TRIAL MONITOR reports on Case 002 are available at <www.krtmonitor.org>, and at the websites of the East-West Center and the War Crimes Studies Center.

[1] It appears from Ong Thong Hoeung's testimony that he was able to keep his journal by chance.

[2] Mr. HorNamhong currently serves as Cambodia's Minister of Foreign Affairs.

[3] The Witness further recounted that he initially declined the position on IengSary's advise, but Pol Pot "wasvery optimistic and he told me I could take up the position and I could work on five stories per day." Asked if hewas in a position to decline an order from Pol Pot, the Witness provided that, "at that time I declined his offerbecause I personally knew Pol Pot very well. I was not really afraid of him, I knew him since I was young. And Ionly learned of what happened during the regime only after 1979; and if I were to know what happened during theregime maybe I would not dare to refuse that offer."

[4] It appears that SuongSikoeun also communicated with Pol Pot through Saur Se, the party secretary at theMFA.

[5] SuongSikoeun recalled that NuonChea, in his capacity as deputy secretary of the party, once tasked him towrite an article on the DK foreign policy. He described this as the only occasion he had contact with NuonChea.

[6] See also Asian International Justice Initiative. KRT Trial Monitor [hereinafter referred to as **CASE 002 KRTTRIAL MONITOR**]. Issue No. 31. Hearing on Evidence Week 26 (6-9 August 2012). 3.

[7] "So Hong" was the alias of Saloth Ban, who also testified before the Trial Chamber in Case 002 from 23 Aprilto 2 May 2012. See CASE 002 KRT TRIAL MONITOR. Issue No. 20, Hearing on Evidence Week 15 (23-26 April2012July). CASE 002 KRT TRIAL MONITOR. Issue No. 21, Hearing on Evidence Week 16 (30 April, 2-3 May 2012).The Witness indicated that although So Hong was Pol Pot's nephew, the leader did not trust him because he was"a person of middle path."

[8] Phy Phuon, whose aliases were "Rochoem Ton" and "Cheam," testified before the Trial Chamber in Case002 from 25 July to 2 august 2012. See CASE 002 KRT TRIAL MONITOR. Issue No. 29 . Hearing on Evidence Week24. (23-26 July 2012).and CASE 002 KRT TRIAL MONITOR. Issue No. 30. Hearing on Evidence Week 25. (30-31July, 1-2 August 2012).

[9] In his OCIJ statement, Suong Sikoeun also expressed that Khieu Samphan "was seen by the Khmer Rouge as a tactical than a strategic force." He explained that the tactical force related to intellectuals who were needed to gather the masses because the CPK believed that they more effective than ordinary students. They were only considered as a strategic force if they refashioned themselves and changed their mentality and adopted the proletarian view.

[10] Suong Sikoeun said he was tasked with preparing the substance of the negotiation, conducting the negotiation, and reporting on it once every two days to Pol Pot, who the Witness said made all the decisions by himself. An agreement was reached on 4 October 1981 in Singapore.

[11] The Witness also expressed that he felt "uneasy" hearing the names of Keat Chhon and Hor Namhong mentioned repeatedly in the proceedings. He asked the parties not to "trouble them," asserting that these individuals were intellectuals who held no power during DK

[12] Sa Siek was unable to recognize the liberation day broadcasts reportedly made by Hu Nim and Khieu Samphan when Prosecutor Abdulhak read these out to her. She was also unable to recall the contents of Khieu Samphan's speech quoted from a transcript of a foreign broadcast.

[13] Sa Siek recounted that Hu Nim was in a Ministry meeting with them sometime in 1976 when he received a phone call from someone he addressed as "Brother." He reportedly drove himself to this meeting and the Witness did not see him again. At 3:00 pm on the same day, a military truck cam to take Hu Nim's wife away.

[14] Khieu Samphan's wife asked Sa Siek and her husband if they knew if Khieu Samphan went to Preak Kdam in 1979 because Khieu Samphan could not remember. The wife of the Accused also told Sa Siek's husband to "tell the whole truth" if investigators asked any question about Khieu Samphan.

[15] The Parties also raised objections to questions on the ground that they were repetitive, irrelevant, or speculative.

[16] See CASE 002 KRT TRIAL MONITOR. Issue No. 24, Hearing on Evidence Week 19 (28-31 May 2012).15-16.

[17] Office of the Co-Prosecutors. Co-Prosecutors' Request for Clarification Regarding the Use of Documents During Witness Testimony (30 May 2012). E201. The OCP requested the Chamber to allow the introduction of documents to witnesses when "sufficiency of the nexus between a document and the direct knowledge of a witness can justify the use of that document."

[18] Trial Chamber. Notice to parties regarding revised modalities of questioning and Response to Co-Prosecutors' Request for Clarification Regarding the Use of Documents During Witness Testimony (13 June 2012). E201_2. 1.

[19] See CASE 002 KRT TRIAL MONITOR. Issue No. 15, Hearing on Evidence Week 10 (19-22 March 2012). 9-10; CASE 002 KRT TRIAL MONITOR. Issue No. 16, Hearing on Evidence Week 11 (26-29 March 2012). 10; CASE 002 KRT TRIAL MONITOR. Issue No. 17, Hearing on Evidence Week 12 (2-5 April 2012). 10.

[20] Ibid.

[21] Ibid.

[22] The telegram dated 10 February 1978 originated from the French Ministry of Foreign Affairs. It related a visit of a Thai delegation to DK in early 1978 and enumerated the Khmer officials they met, including Pol Pot, Ieng Sary, Thiounn Prasith, and Keat Chhon.

[23] Abdulhak justified the use the transcript by referring to the OCP's submission and the Chamber's Notice to Parties –

> [i]f we're in the business of searching for and finding the truth, then it's about theinformation in the document and whether or not the witness is familiar with that information, whether she recognizes it. We filed the motion on this seeking to clarify the way in which the ruling is intended to operate. This was one of the basis that we put forward and Your Honours agreed with us, and I think we're just seeking to act consistently with that ruling.

[24] Pauw stated that after reviewing Suong Sikoeun's testimony, he found that, "not every time that a document is shown to the witness is the witness asked whether or not he has seen that document, and for that reason the document is not removed from the witness if he does not -- if he has not seen that document immediately." Judge Cartwright interrupted him, stating that this will be discussed in more general terms at the scheduled trial management meeting.

[25] See IR 88.2.

[26] Notably, the three witnesses knew each other from their work with the MFA during the regime. Presently, all of them live in Malai District, Banteay Meanchey Province. Sikoeun contacted Phy Phuon more often because Sikoeun said he treated Phy Phuon as a younger brother due to their shared memories.

[27] CASE 002 KRT TRIAL MONITOR. Issue No. 30. Hearing on Evidence Week 25. (30-31 July, 1-2 August 2012). 11.

[28] CASE 002 KRT TRIAL MONITOR. Issue No. 6. Hearing on Evidence Week 1. (5-9 December 2011). 9.

[29] According to Lars Olsen, Legal Communications Officer of the ECCC's Public Affairs Section, "There was a WESU rep there, and the reason the WESU rep was there was to monitor that they did not discuss case-related issues." See White, Stuart. "Khmer Rouge court witnesses' meeting scrutinized." Phnom Penh Post. (21 August 2012). Available at <http://www.phnompenhpost.com/index.php/KRTalk/khmer-rouge-court-witnesses-meeting-scrutinised.html> last accessed on 31 August 2012.

[30] Chhorn Chansy and Julia Wallace. "KRT Witness Recants Hor Namhong Claim." Cambodia Daily (13 August 2012). 17.

[31] See IR 28.1.

[32] See IR 24.1.

[33] See IR 85 and 87.3.

[34] See CASE 002 KRT TRIAL MONITOR. Issue No. 23. Hearing on Evidence Week 18 (21, 23 May 2012). 3-4.

WSD**HANDA**CENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University

**This publication was originally produced pursuant to a project supported by the War Crimes Studies Center (WCSC), which was founded at the University of California, Berkeley in 2000. In 2014, the WCSC re-located to Stanford University and adopted a new name: the WSD Handa Center for Human Rights and International Justice. The Handa Center succeeds and carries on all the work of the WCSC, including all trial monitoring programs, as well as partnerships such as the Asian International Justice Initiative (AIJI).**

**A complete archive of trial monitoring reports is available online at:**

**http://handacenter.stanford.edu/reports-list**

**For more information about Handa Center programs, please visit:**

**http://handacenter.stanford.edu**